**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# បណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមព្រហ្មទណ្ឌ

ស្រាវជ្រាវពី ថ្ងៃទី **២៧** ខែ មេសា ដល់ ថ្ងៃទី **២៥** ខែ មិថុនា ឆ្នាំ **២០២១**


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **គួច រ៉ូសរីម៉ី**

កញ្ញា **ជីន ដាលីន**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២១**

ឆ្នាំចូលសិក្សា **២០១៧**

ឆ្នាំសរសេរសារណា **២០២១**

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបញ្ចប់ថ្នាក់ បរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី២១ របស់ខ្លួនដោយការសរសេរសារណាជាថ្នូរនៃការបញ្ចប់ការសិក្សា និងបង្ហាញពីសមត្ថភាពដែលបានសិក្សាក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ។

និស្សិត **គួច វ៉ូសរីម៉ី**

និស្សិត **ឌីន ដាលីន**

នាងខ្ញុំទាំងពីរសូមធ្វើការសម្តែងនូវទឹកចិត្ត និងការថ្លែងអំណរគុណដល់៖

ចំពោះ លោកឪពុក **ឌួច នាថ** អ្នកម្តាយ **ស៊ិញ្ញទ្រី អ៊ឹម** និង លោកឪពុក **ជិន ឌីន** អ្នកម្តាយ **សៅ សុខឡេង** ដែលលោកអ្នកមានគុណទាំងទ្វេដែលបានផ្តល់កំណើតដល់យើងខ្ញុំ មើលថែរ អប់រំ ទូន្មានប្រៀនប្រដៅ ឧបត្ថម្ភរូបកូន នូវសម្ភារៈ លុយកាក់ សំលៀកបំពាក់ គ្រប់សព្វបែបយ៉ាង តាំងពីកូននៅតូចរហូតដល់កូនធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ និង បានឲ្យកូនបានរៀនសូត្រមានចំណេះ ដឹងតាំងពីថ្នាក់តូច រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្ររហូតដល់ជោគជ័យ។ គុណធំអនេក និងវិសេសវិសាលថ្លៃថ្លា បំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរ ដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូប មានទំហំធំធេង រកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងពីរធ្វើឲ្យកូនៗចងចាំជានិច្ចគ្មានថ្ងៃ បំភ្លេចបានហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសាបសូន្យនោះឡើយ។

នាងខ្ញុំឈ្មោះ **ឌីន ដាលីន** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង សម្តេចកិត្តិព្រឹទ្ធ ប៊ុន រ៉ានី ហ៊ុន សែន** តាមរយៈ ឯកឧត្តម **ហ៊ុន ម៉ាណែត** ដែលបានផ្តល់អាហារូបករណ៍រយៈពេលបួនឆ្នាំដល់រូបនាងខ្ញុំ។

ទន្ទឹមនេះផងដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច។ ម្យ៉ាងវិញទៀតសូមថ្លែងអំណរគុណចំពោះ ថ្នាក់ដឹកនាំ លោក-លោកស្រីសាស្ត្រាចារ្យ គណៈគ្រប់គ្រង និង បុគ្គលិក ទាំងអស់ ដែលបានខិតខំក្នុងការបង្ហាត់បង្រៀនផ្តល់នូវដំបូន្មាន និងបទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ ដោយមិនខ្វល់ពីការនឿយហត់ ក្នុងគោលបំណងផ្តល់នូវចំណេះដឹងដ៏ច្បាស់លាស់ និងដើម្បីជាប្រទីបក្នុងការបំភ្លឺផ្លូវជីវិតរហូត ដល់ថ្ងៃអនាគត។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឲ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើង ប្រកបដោយជោគជ័យ។ ជាពិសេសលោកបាន ចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ តម្រង់ទិសណែនាំឯកសារ ដែលពាក់ពន្ធ័និងសារណា ផ្តល់អនុសាសន៍ល្អៗ និងជួយកែលំអរចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណា ឲ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរ សូមគោរពជូនពរដល់**លោកអ្នកមានគុណទាំងទ្វេ សម្តេចទាំងពីរ ឯកឧត្តម សាកលវិទ្យាធិការ លោក-លោកស្រី សាស្ត្រាចារ្យ គណៈគ្រប់គ្រង និងបុគ្គលិក គ្រប់រូប** សូមទទួលបាននូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី ០៤ ជំនាន់ទី **២១** ដោយឆ្លងកាត់ពេលវេលា បួនឆ្នាំកន្លងមក យើងខ្ញុំទាំងពីរនាក់ទទួលបានចំណេះដឹងយ៉ាងទូលំទូលាយទាក់ទងនឹងវិស័យច្បាប់ ក្រោមការបង្ហាត់បង្រៀនពីសំណាក់សាស្ត្រាចារ្យជាច្រើនរូបតាមជំនាញនីមួយៗ មានបទពិសោធន៍ជាច្រើនទាំងក្នុងការបង្រៀន និងការប្រតិបត្តិផ្នែកវិជ្ជាជីវៈផ្ទាល់។ នាងខ្ញុំទាំងពីរមានក្តីសោមនស្សរីករាយ ដែលសាកលវិទ្យាល័យបានផ្តល់ឱកាសដល់នាងខ្ញុំទាំងពីរ បញ្ចេញនូវសមត្ថភាពខាងទ្រឹស្តីដែលបានសិក្សារយៈពេល០៤ឆ្នាំកន្លងមកនេះ ដើម្បីសរសេរចងក្រងជាសារណាបញ្ចប់ការសិក្សាមួយនេះឡើង។

ការរៀបចំសារណានេះឡើង ក្នុងគោលបំណងដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ យើងខ្ញុំក៏បានស្រាវជ្រាវសារណានេះឡើង ដោយទាក់ទងទៅនឹងផ្នែកនីតិសាស្ត្រ ដែលមានប្រធានបទស្តីពី **បណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ។** នាងខ្ញុំទាំងពីរនាក់ បានពិពណ៌នាអំពី នីតិវិធី និងដំណើរការបណ្តឹងទាស់និងបណ្តឹងឧទ្ធរណ៍ នៅក្នុងរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីដែលបានរៀបរាប់ក្នុងសារណានេះ បានដកស្រង់ចេញពីប្រភពច្បាប់ជាធរមានរបស់ ព្រះរាជាណាចក្រកម្ពុជាជាពិសេស ក្រមនីតិវិធីព្រហ្មទណ្ឌ និងឯកសារពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្នរបស់បណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍ ។

យើងខ្ញុំជឿជាក់ថា អត្ថបទស្រាវជ្រាវនេះជាឯកសារដ៏សំខាន់ ដែលវាអាចជំនួយដល់សិស្ស និស្សិតជំនាន់ក្រោយ រួមទាំង ប្រជាពលរដ្ឋក្នុងការស្រាវជ្រាវអំពី ដំណើរការប្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍ នៅស្ថាប័នតុលាការ។

ជាចុងបញ្ចប់ យើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់ចំណុចខ្វះខាតមួយចំនួនដែលកើតឡើង ក្នុងសារណា របស់យើងខ្ញុំ ដូចជាការខុសឆ្គង ទៅលើពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ ឬ អក្ខរាវិរុទ្ធ ទាំងឡាយ នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយក្តីអនុគ្រោះ។ នាងខ្ញុំសូមស្វាគមន៍រាល់នូវការរិះគន់ដើម្បីស្ថាបនា។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ **១**

**ជំពូកទី១**

**បណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ**

**ផ្នែកទី១៖ បណ្តឹងទាស់លើសាលក្រមកំបាំងមុខ** .................................. **៤**

**១.និយមន័យ** ............................................................ **៤**

**២.សាលក្រមដែលអាចប្តឹងទាស់** .................................................. **៤**

**៣. បុគ្គលដែលអាចប្តឹងទាស់បាន** ................................................. **៥**

៣.១. ពិរុទ្ធជន ............................................................ ៥

៣.២. ដើមបណ្តឹងរដ្ឋប្បវេណី .................................................. ៥

៣.៣. អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ............................................. ៧

**៤.រយៈពេលនៃការធ្វើបណ្តឹងទាស់** ................................................ **៧**

៤.១.រយៈពេលប្តឹងទាស់របស់ពិរុទ្ធជន ............................................ ៧

៤.២.រយៈពេលធ្វើបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ............................... ៨

៤.៣.រយៈពេលធ្វើបណ្តឹងទាស់របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ......................... ៨

**៥.អានុភាពនៃបណ្តឹងទាស់** ...................................................... **៩**

**ផ្នែកទី២៖ បណ្តឹងឧទ្ធរណ៍ទៅលើសាលក្រមព្រហ្មទណ្ឌ** .............................. **១១**

**១.និយមន័យ** ............................................................ **១១**

**២.សាលក្រមដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បាន** ......................................... **១១**

២.២.១.សាលក្រមដែលទាក់ទងនឹងសមត្ថកិច្ចសាលាដំបូង ................................ ១៣

២.២.២.សាលក្រមពិភាក្សាដេញដោលជាសម្ងាត់ ....................................... ១៤

២.២.៣.សាលក្រមដែលបង្គាប់ធ្វើការស៊ើបសួរបន្ថែម ...................... ១៤

២.២.៤.សាលក្រមជំនុំជម្រះលើរឿងអញ្ញត្រកម្ម ...................... ១៥

**៣.សាលក្រមអន្តសេចក្តី ...................... ១៦**

៣.១. សាលក្រមចំពោះមុខ ...................... ១៦

**៣.១.១.សាលក្រមចំពោះមុខជនជាប់ចោទ** ...................... ១៦

**៣.១.២.សាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី** ...................... ១៦

**៣.១.៣.សាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី** ...................... ១៦

៣.២. សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ...................... ១៧

៣.៣.សាលក្រមកំបាំងមុខ ...................... ១៧

**៤.បុគ្គលដែលអាចប្តឹងឧទ្ធរណ៍បាន ...................... ១៧**

៤.១.បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ...................... ១៨

៤.២. បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ...................... ១៨

៤.៣. បណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ...................... ១៨

**៥.រយៈពេលសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ ...................... ១៩**

៥.១. រយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ...................... ១៩

៥.២. រយៈពេលបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ...................... ១៩

៥.៤. រយៈពេលបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ...................... ២០

**៦.អានុភាពនៃបណ្តឹងឧទ្ធរណ៍ ...................... ២០**

៦.១. អានុភាពនៃបណ្តឹងឧទ្ធរណ៍ទៅលើការអនុវត្តសាលក្រម ...................... ២០

៦.២. អានុភាពនៃបណ្តឹងឧទ្ធរណ៍លើជនជាប់ចោទ ...................... ២១

៦.៣. អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ...................... ២១

៦.៤. អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ...................... ២១

៦.៥.អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ...................... ២២

៦.៦.បណ្តឹងឧទ្ធរណ៍ដែលមិនអាចទទួលយកបាន ..... ២២
៦.៧. ការបដិសេធសាលក្រម ..... ២២

## ជំពូកទី២

## ការអនុវត្តនីតិវិធីនៃការធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍

**ផ្នែកទី១៖ នីតិវិធីនៃការធ្វើបណ្តឹងទាស់ ..... ២៣**
**១.នីតិវិធីមុនពេលដាក់ពាក្យបណ្តឹង ..... ២៣**
១.១.ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ..... ២៣
១.១.១.ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការដោយព្រះរាជអាជ្ញា ..... ២៤
១.១.២.ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការដោយអាជ្ញាសាលា ..... ២៤
១.២.ការចាប់ខ្លួនជនជាប់ចោទ ..... ២៤
**២.នីតិវិធីក្នុងពេលដាក់ពាក្យបណ្តឹងទាស់ ..... ២៥**
២.១.ការដាក់ពាក្យបណ្តឹងទាស់ ..... ២៥
២.១.១.បណ្តឹងធ្វើឡើងជាលាយលក្ខណ៍អក្សរ ..... ២៦
២.១.២.បណ្តឹងធ្វើឡើងដោយផ្ទាល់មាត់ ..... ២៦
២.២.ការពិនិត្យពាក្យបណ្តឹងទាស់ ..... ២៦
**៣.នីតិវិធីក្រោយពេលទទួលបណ្តឹងទាស់ ..... ២៦**
៣.១.ការកំណត់កម្មវិធីជំនុំជម្រះជាថ្មី ..... ២៦
៣.១.១.រយៈពេលកំណត់ឱ្យចូលបង្ហាញខ្លួននាពេលសវនាការ ..... ២៧
៣.១.២.ការប្រគល់ដីកាកោះហៅដោយព្រះរាជអាជ្ញា ..... ២៧
៣.១.៣.របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅ ..... ២៧
៣.១.៤.ទម្រង់ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ ..... ២៨
៣.១.៥.ទម្រង់ដីកាកោះហៅដើមបណ្តឹងឱ្យចូលសវនាការ ..... ២៨
៣.១.៦.ទម្រង់ដីកាកោះហៅជនរងគ្រោះឱ្យចូលសវនាការ ..... ២៨
៣.១.៧.ទម្រង់ដីកាកោះហៅសាក្សីឱ្យចូលសវនាការ ..... ២៩

៣.១.៨.ទម្រង់ដីកាកោះហៅអ្នកជំនាញឱ្យចូលសវនាការ ........ ២៩

៣.១.៩.ទម្រង់ដីកាកោះហៅអ្នកបកប្រែឱ្យចូលសវនាការ ........ ៣០

៣.១.១០.ទម្រង់ដីកាកោះហៅអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឱ្យចូលសវនាការ ........ ៣០

៣.២.ការសម្រេចលើបណ្ដឹងទាស់ ........ ៣០

**ផ្នែកទី២៖ នីតិវិធីនៃការធ្វើបណ្ដឹងឧទ្ធរណ៍ ........ ៣២**

**១.ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ........ ៣២**

១.១.ការប្រកាសបណ្ដឹងឧទ្ធរណ៍ដោយពិរុទ្ធជនដែលជាប់ឃុំ ........ ៣២

១.២.ទម្រង់នៃបណ្ដឹងឧទ្ធរណ៍ ........ ៣២

១.២.១.ទម្រង់នៃបណ្ដឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ........ ៣២

១.២.២.ទម្រង់នៃបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ........ ៣៣

**២.ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ ........ ៣៣**

**សេចក្ដីសន្និដ្ឋាន ........ ៣៤**

**អនុសាសន៍ ........ ៣៥**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំនៃការស្រាវជ្រាវ

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ដែលអំណាចតុលាការជាអំណាចឯករាជ្យ ធានារក្សាអនាគតិ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ ហើយមានតែមានតែស្ថាប័នអយ្យការទេ ដែលជាតំណាងឱ្យសង្គម និងតំណាងឱ្យប្រទេសជាតិ ហើយក៏ជាម្ចាស់នៃបណ្តឹងអាជ្ញា។ មានតែចៅក្រមទេដែលមានសិទ្ធិជំនុំជម្រះក្តី។ ដំណើរការនៃការជំនុំជម្រះក្តីដែលប្រព្រឹត្តទៅតាមលំហូរនៃនីតិវិធីច្បាប់ គឺជាចំណុចសំខាន់នៃការការពារនិងគោរពសិទ្ធិមនុស្ស និងជាប្រសិទ្ធភាពនៃស្ថាប័នតុលាការផងដែរ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ហេតុនេះហើយមនុស្សគ្រប់រូបមានសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ នេះមានន័យថាទោះបីជាជននោះ ជាជនសង្ស័យក៏ដោយ ជននោះត្រូវចាត់ទុកថាគ្មានទោសរហូតទាល់តែមានសាលក្រមព្រហ្មទណ្ឌស្ថាពរ។ សាលក្រមព្រហ្មទណ្ឌ គឺជាសេចក្តីសម្រេចលើរឿងក្តីព្រហ្មទណ្ឌរបស់សាលាដំបូង បន្ទាប់ពីបានបើកសវនាការធ្វើការពិភាក្សាដេញដោល និងប្រកាសសាលក្រម។ សាលក្រមនឹងត្រូវបានយកទៅអនុវត្តចំពោះជនជាប់ចោទនៅពេលដែលសាលក្រមនោះចូលជាស្ថាពរ បើពុំដូច្នេះទេ មិនអាចធ្វើការអនុវត្តបានឡើយ។ ប្រព័ន្ធបណ្តឹង ក៏ដូចជាផ្លូវក្នុងការធ្វើបណ្តឹងចំពោះសេចក្តីសម្រេច គេសង្កេតឃើញថាត្រូវបានចែកជាពីរគឺៈ ប្រព័ន្ធបណ្តឹងបដិរូបកម្ម គឺជាផ្លូវមួយដែលទាមទារឱ្យតុលាការចេញសេចក្តីសម្រេចមួយថ្មីទៀត ដើម្បីកែប្រែសេចក្តីសម្រេចដើម ហើយវាត្រូវបានចេញដោយតុលាការដែលមានឋានានុក្រមខ្ពស់ជាង ដែលអាចធ្វើបានតាមរយៈបណ្តឹងឧទ្ធរណ៍ (ត្រូវធ្វើបណ្តឹងក្នុងអំឡុងពេលមួយ ដែលមិនផុតរយៈពេលសម្រាប់ធ្វើការប្តឹង។ ផ្លូវបណ្តឹងមួយទៀត គេហៅថា ជាផ្លូវនៃបណ្តឹងដែលនាំឱ្យតុលាការប្រែក្រឡាស់សម្តី ចំពោះសេចក្តីសម្រេចដែលខ្លួនបានចេញរួចហើយ ដោយមានការទាមទារពីភាគីក្នុងរឿងក្តី ចំពោះសាលក្រមកំបាំងមុខចំពោះអង្គសេចក្តីវិញតុលាការដដែលជាអ្នកមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្តឹងប្រភេទនេះ។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

ដើម្បីជាការយល់ដឹងឱ្យកាន់តែស៊ីជម្រៅ បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមព្រហ្មទណ្ឌ យើងខ្ញុំបានកំណត់នូវសំណួរស្រាវជ្រាវនៅសំណួរស្រាវជ្រាវមួយចំនួនដូចជាៈ

- អ្វីជាសាលក្រមព្រហ្មទណ្ឌ ?
- អ្វីជាបណ្តឹងទាស់ និងអ្វីជាបណ្តឹងឧទ្ធរណ៍ ?
- បុគ្គលណាខ្លះដែលអាចធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍បាន ?
- រយៈពេលនៃការធ្វើបណ្តឹង ?
- អានុភាពសាលក្រមនាពេលមានបណ្តឹង ?

## ៣.គោលបំណងក្នុងការសរសេរសារណា

ចំពោះការស្រាវជ្រាវនេះ មានគោលបំណងចង់ចែករំលែកនូវចំណេះដឹងខ្លះៗ ឬមួយផ្នែកអំពីប្រធានបទស្តីពីបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ ដោយហេតុថា តើការធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍មានសារៈសំខាន់យ៉ាងណាខ្លះចំពោះភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្តី ឬវិស័យយុត្តិធម៌ទាងមូល ? ហើយយើងខ្ញុំជឿជាក់ថា ការស្រាវជ្រាវនេះជាវណ្ណកម្មមួយសម្រាប់ជាជំនួយដល់និស្សិតដែលមានបំណងចង់ស្វែងយល់បន្ថែមអំពី ការធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ។

## ៤.ដែនកំណត់ និងវិសាលភាព នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទ "បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រម" យើងខ្ញុំធ្វើការផ្តោតសំខាន់ សាលក្រម បុគ្គលដែលអាចធ្វើបណ្តឹង រយៈពេលនៃការធ្វើបណ្តឹង អានុភាពនៃសាលក្រមនាពេលមានបណ្តឹង និងនីតិវិធីនៃការធ្វើបណ្តឹង រីឯនីតិវិធីនៅសាលាឧទ្ធរណ៍ យើងខ្ញុំមិនលើកយកមកធ្វើការសិក្សាស្រាវជ្រាវនោះទេ។

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការដំណើការនៃការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ យើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវដោយប្រមូលទិន្នន័យឯកសារផ្សេងៗដែលទាក់ទងជាមួយនឹងប្រធានបទរបស់យើងខ្ញុំនៅតាមប្រព័ន្ធអ៊ីនធើណេត និងការស្រាវជ្រាវតាមរយៈឯកសារច្បាប់នានាដែលមានធរមានដូចខាងក្រោម៖

- ការស្រាវជ្រាវតាមរយៈឯកសារច្បាប់
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
  - ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ ២០១៤
  - ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
- សៀវភៅដែលជាឯកសារបស់សាស្ត្រាចារ្យមួយចំនួន
  - មេរៀន បច្ចេកទេសតាក់តែងសាលក្រមព្រហ្មទណ្ឌ របស់លោក សេង នាង ជាគ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
  - មេរៀន បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ របស់លោក ប៉ុន សារ៉ាត ជាគ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានចែកចេញជា ០២ ជំពូក៖

# ជំពូកទី១ បណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ

# ជំពូកទី២ ការអនុវត្តនីតិវិធីនៃការធ្វើបណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍

# ជំពូកទី១

# បណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ

## ផ្នែកទី១៖ បណ្តឹងទាស់លើសាលក្រមកំបាំងមុខ

### ១.និយមន័យ

បណ្តឹងទាស់ គឺជាផ្លូវតវ៉ាដែលធ្វើឡើងដើម្បីប្រឆាំងនឹងសាលក្រមកំបាំងមុខ ដែលបានចេញកំបាំងជនជាប់ចោទ។ ពិរុទ្ធជន អាចធ្វើបណ្តឹងទាស់នឹង សាលក្រមដែលប្រកាសកំបាំងមុខខ្លួនបាន[1]។ មានន័យថា នៅពេលដែលជនជាប់ចោទ មិនបានបង្ហាញខ្លួននៅសវនាការទេ ឬមិនបានបង្ហាញភស្តុតាងឲ្យសាមីខ្លួនដឹងពី ការបញ្ជូនទៅជំនុំជម្រះ ឬបានដឹងពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ ហើយសាលក្រមនេះបានបើកផ្លូវប្តឹងទាស់[2]។

### ២.សាលក្រមដែលអាចប្តឹងទាស់

សាលក្រមដែលអាចប្តឹងទាស់បានគឺ សាលក្រមកំបាំងមុខ។

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលតុលាការប្រកាសកំបាំងមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដែលអវត្តមាននៅក្នុងពេលសវនាការ។ ប្រសិនបើ ជនជាប់ចោទមិនបានចូលខ្លួននៅក្នុងពេលសវនាការទេ ហើយប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថាសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ តុលាការនឹងប្រកាសសាលក្រមកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមកំបាំងមុខអាចប្តឹងទាស់បាន[3]។

ប្រសិនបើ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាទេ នឹងគ្មានអ្នកតំណាងត្រឹមត្រូវទេ នោះតុលាការនឹងចេញសាលក្រមកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខអាចប្តឹងទាស់បាន[4]។

ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ ហើយគ្មានអ្នកតំណាងត្រឹមត្រូវទេនោះតុលាការ នឹងចេញសាលក្រមកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខ ត្រូវជូនដំណឹងដល់អ្នកទទួលត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះអាចប្តឹងទាស់បាន[5]។

---

[1] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[2] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[3] មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[4] មាត្រា ៣៦៣ វាក្យខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[5] មាត្រា ៣៦៤ វាក្យខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

## ៣. បុគ្គលដែលអាចប្តឹងទាស់បាន

ជាទូទៅសាលក្រម ឬសាលដីកាកំបាំងមុខ គឺបើកសិទ្ធិឱ្យភាគីពាក់ព័ន្ធអាចធ្វើបណ្តឹងទាស់ប្រឆាំងនឹងសេចក្តីសម្រេចនោះ ភាគីទាំងនោះមានដូចខាងក្រោម :

- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី ឬ
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

### ៣.១. ពិរុទ្ធជន

ជាធម្មតានៅពេលដែលតុលាការប្រកាសពិរុទ្ធភាពទៅលើជនជាប់ចោទ តាមរយៈសាលក្រម ឬ សាលដីកា (ចំពោះមុខ ឬកំបាំងមុខ) ជននោះនឹងក្លាយទៅជាពិរុទ្ធជន ។ ចំពោះករណីដែលសាលក្រម ឬសាលដីកាប្រកាសជាកំបាំងមុខនោះ បើពិរុទ្ធជនមិនសុខចិត្តទៅនឹងសេចក្តីសម្រេចនេះ ពិរុទ្ធជនអាចធ្វើ បណ្តឹងទាស់នឹងសេចក្តីសម្រេចនោះបាន[6]។

### ៣.២. ដើមបណ្តឹងរដ្ឋប្បវេណី

បុគ្គលដែលរងទុក្ខទោស ឬការអន្តរាយដោយសារបទល្មើសព្រហ្មទណ្ឌណាមួយ ដែលគេហៅថា ជនរងគ្រោះ ដែលអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានតាមរយៈបណ្តឹងរដ្ឋប្បវេណី[7] ប៉ុន្តែមិនមាន ន័យថាមានតែជនរងគ្រោះទេដែលអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាននោះទេ ការតាំងខ្លួននោះក៏ អាចជាតតិយជនហេតុនេះ(តើនរណាខ្លះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន) នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាបុគ្គលដែល អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានមានដូចខាងក្រោម :

- ជនរងគ្រោះ
- អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះជាអនីតិជន
- អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះដែលស្ថិតក្រោមរបបច្បាប់ការពារ
- បុគ្គល ឬសមាគមដទៃទៀតដែលច្បាប់អនុញ្ញាតឱ្យប្រើប្រាស់សិទ្ធិ ដែលទទួលស្គាល់ដល់ ដើមបណ្តឹងរដ្ឋប្បវេណី[8]។

ប៉ុន្តែអ្វីដែលសំខាន់ គឺថាជនដែលរៀបរាប់ខាងលើអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ពេលបានទេ មានន័យថាបុគ្គលទាំងនោះត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ដែលលក្ខខណ្ឌនោះមានការជិតស្និតទៅនឹង

---

[6] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[7] មាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[8] មាត្រា ១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

គោលការណ៍ព្យសនកម្ម ព្រោះថាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងជួសជុលព្យសនកម្ម ដែលជាផលវិបាកនៃបទល្មើស តើលក្ខខណ្ឌទាំងនោះមានអ្វីខ្លះ? ដោយយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាដើម្បីទទួលការជួសជុលបាន ព្យសនកម្មនោះត្រូវតែ៖

- ជាផលវិបាកផ្ទាល់នៃបទល្មើស៖ មានន័យថាព្យសនកម្មនេះ គឺពិតជាលទ្ធផលស្តែងដែលបណ្តាលមកពីបទល្មើស។
- ជាព្យសនកម្មផ្ទាល់ខ្លួន៖ សំដៅទៅលើជនរងគ្រោះដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាល់តែអះអាងថាខ្លួនឯងផ្ទាល់ពិតជាអ្នកដែលរងព្យសនកម្មពិតប្រាកដ។
- បានកើតឡើង នៅក្នុងពេលបច្ចុប្បន្ន៖ ព្យសនកម្មដែលកើតចេញពីបទល្មើសនៅក្នុងពេលបច្ចុប្បន្ន ជនរងគ្រោះមិនអាចទាមទារសំណង ដែលខ្លួនយល់ឃើញថានឹងកើតឡើងនាពេលអនាគតបានទេ។

ក្រោយពីបានបង្ហាញអំពីលក្ខខណ្ឌ នៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហើយ យើងត្រូវដឹងថាតើនៅពេលណាដែលជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចតាំងខ្លួនបាននោះ? ចំពោះការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងនីតិវិធីយើងខ្ញុំសូមបែងចែកជាបីដូចខាងក្រោម៖

- ទី១៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹងដើម៖ មានន័យថា ជាទូទៅនៅពេលដែលជនរងគ្រោះបានប្តឹងអំពីបទល្មើសដែលបានកើតឡើង ដែលការប្តឹងនោះអាចធ្វើនៅមុខចំពោះមន្ត្រីនគរបាលយុត្តធម៌ ឬ ព្រះរាជអាជ្ញា ហើយការប្តឹងរបស់គាត់នោះមានការទាមទារសំណងការខូចខាត ដែលហៅថា បណ្តឹងរដ្ឋប្បវេណី។ ការប្តឹងបែបនេះគេហៅថា ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង។[9]
- ទី២៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍៖ ការតាំងខ្លួនប្រភេទនេះសំដៅថា ជនរងគ្រោះមិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលខ្លួនប្តឹងនោះទេ បានន័យថាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ គឺជាការតាំងខ្លួន នៅដំណាក់កាលស៊ើបសួរ នៅចំពោះមុខចៅក្រមស៊ើបសួរបន្ទាប់ពីព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។[10]
- ទី៣៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ មិនត្រឹមតែជនរងគ្រោះ អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមបណ្តឹង និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍

---

[9] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[10] មាត្រា ១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

នោះទេ ជនរងគ្រោះក៏អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសវនាការក៏បានដែរ ប៉ុន្តែការតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលបានទេ ក្រោយពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តី[11]។

ទោះបីជាយ៉ាងណាក៏ដោយបុគ្គល ឬជនរងគ្រោះ នៅពេលដែលគាត់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហើយ បុគ្គលនោះមិនអាចត្រូវបានគេស្តាប់ចម្លើយក្នុងឋានៈជាសាក្សីបានទេ[12]។

### ៣.៣. អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ជាទូទៅ បើរកឃើញថាមានទោស ជនជាប់ចោទ ត្រូវទទួលខុសត្រូវអំពីការខូចខាតដែលបណ្តាលមកពីទង្វើរបស់ខ្លួន។ ក្នុងករណីមួយចំនួន តតិយជនអាចទទួលខុសត្រូវសំណងរដ្ឋប្បវេណី ដែលហៅថាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ដូច្នេះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជាបុគ្គលដែលត្រូវទទួលខុសត្រូវចំពោះផលវិបាកខាងផ្នែករដ្ឋប្បវេណីនៃបទល្មើសដែលប្រព្រឹត្តដោយជនជាប់ចោទដែលបណ្តាលឱ្យមានចំពោះជនរងគ្រោះ[13]។

ឧទាហរណ៍ : ឪពុកម្តាយរបស់ជនជាប់ចោទអាយុ ១៦ ឆ្នាំ អាចត្រូវទទួលខុសត្រូវ សំណងខូចខាតដែលបណ្តាលមកពីបទល្មើសប្រព្រឹត្តដោយកូនរបស់ខ្លួន ។

ក្រោយពីបានដឹងអំពីភាគីដែលអាចធ្វើបណ្តឹងទាស់ហើយ យើងឃើញថាមានតែពិរុទ្ធជន ដើមបណ្តឹង-រដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ប៉ុន្តែគួរកត់សំគាល់ថា តើព្រះរាជអាជ្ញាដែលជាភាគីដើមក្នុងរឿងព្រហ្មទណ្ឌតាមរយៈបណ្តឹងអាជ្ញា តើគាត់អាចធ្វើបណ្តឹងទាស់ដែរឬទេ? ត្រង់បញ្ហានេះយើងគួរយល់ថាព្រះរាជអាជ្ញាភាគីរបស់តុលាការ ហើយដើម្បីធានាឱ្យមាននិយ័តភាពនៃសេចក្តីសម្រេចរបស់តុលាការ ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ តែប្រសិនបើពេលសវនាការ ព្រះរាជអាជ្ញាអវត្តមាន អាចបណ្តាលឱ្យមានការលើកសវនាការ ហេតុនេះមិនមានលក្ខខ័ណ្ឌណាដែលព្រះរាជអាជ្ញាអវត្តមាននៅសវនាការទេ ដែលជាមូលហេតុមួយដែលគ្មានសេចក្តីសម្រេចកំបាំងមុខចំពោះព្រះរាជអាជ្ញាទេហើយគាត់ក៏មិនអាចធ្វើបណ្តឹងទាស់បាននោះដែរ ។

## ៤.រយៈពេលនៃការធ្វើបណ្តឹងទាស់

### ៤.១.រយៈពេលប្តឹងទាស់របស់ពិរុទ្ធជន

បណ្តឹងទាស់ត្រូវធ្វើឡើងនៅក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ ផ្តើមគិតពី៖

[11] មាត្រា ៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[12] មាត្រា ៣១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[13] មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

- ថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដីកាកោះហៅ នឹងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ) នៃក្រមនេះ[14]។

## ៤.២.រយៈពេលធ្វើបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងទាស់ត្រូវធ្វើឡើងនៅក្នុងរយៈ ១៥(ដប់ប្រាំ)ថ្ងៃ គិតពីៈ

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណើរការនៃសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) នៃក្រមនេះ។

បណ្តឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម[15]។

## ៤.៣.រយៈពេលធ្វើបណ្តឹងទាស់របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

បណ្តឹងទាស់ត្រូវធ្វើឡើងនៅក្នុងរយៈ ១៥(ដប់ប្រាំ)ថ្ងៃ គិតពីៈ

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ

[14] មាត្រា ៣៦៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[15] មាត្រា ៣៧២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

- ថ្ងៃដែលអ្នកទទួលខុសត្រូវរដ្ឋប្បវេណី បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណើរការនៃសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្លីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) នៃក្រមនេះ។

បណ្តឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម។

## ៥.អានុភាពនៃបណ្តឹងទាស់

ជាគោលការណ៍នៅពេលមានបណ្តឹងទាស់ ការអនុវត្តសេចក្តីសម្រេចត្រូវបានព្យួរ មួយផ្នែកឬទាំងមូល ដូចដែលបានបង្ហាញរៀបរាប់នៅក្នុងផ្នែកនិយមន័យ នៃបណ្តឹងទាស់ ប៉ុន្តែអ្វីដែលសំខាន់យើងសូមធ្វើការបែងចែកអានុភាពជាពីរធំៗគឺ៖

- **<u>អានុភាពនៃដីកាបង្គាប់ឲ្យចាប់ខ្លួន</u>៖** នៅពេលជនជាប់ចោទអវត្តមាននៅពេលសវនាការ ដែលជាមូលហេតុមួយ ដែលតុលាការអាចសម្រេចលើអង្គសេចក្តីដោយកំបាំងមុខទៅលើជនជាប់ចោទនោះ ហើយនៅពេលខ្លះតុលាការអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនពិរុទ្ធជន ដែលអវត្តមាននៅពេលមានសវនាការតែម្តង ហេតុនេះយើងត្រូវយល់សិនថា តើលក្ខខណ្ឌណាខ្លះទើបតុលាការចេញដីកាបង្គាប់ឲ្យចាប់ខ្លួននៅពេលសវនាការ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ យើងឃើញថានៅពេលដែល តុលាការប្រកាសសេចក្តីសម្រេចកំបាំងមុខជនជាប់ចោទ ហើយផ្តន្ទាទោសដាក់ពន្ធនាគារត្រូវចាប់ពី ១ឆ្នាំ ដោយគ្មានការព្យួរ ដែលលក្ខខណ្ឌទាំងនេះអាចឲ្យតុលាការចេញ ដីកាបង្គាប់ឲ្យចាប់ខ្លួននៅពេលសវនាការតែម្តង ដីកានេះគឺមានអានុភាពភ្លាមៗ[16]។ ក្នុងករណី ដែលមានការប្តឹងទាស់របស់ពិរុទ្ធជនក៏ដោយ ក៏ដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែមានអានុភាព មានន័យថាធ្វើយ៉ាងណាឲ្យតែពិរុទ្ធជននៅក្នុងឃុំ។ ដោយឃើញអានុភាពទីមួយមានការប៉ះពាល់ដល់សិទ្ធិ សេរីភាពពិរុទ្ធជន ហេតុនេះក្រមនីតិវិធីព្រហ្មទណ្ឌបានបង្កើតអានុភាពទីពីរដើម្បីលុបបំបាត់គុណវិបត្តិនៃអានុភាពទីមួយ។

[16] មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- **<u>អានុភាពទាក់ទងនឹងរឿងឃុំខ្លួនពិរុទ្ធជន៖</u>** ដូចបានរៀបរាប់ខាងលើ ទោះបីជាពិរុទ្ធជនបានធ្វើបណ្តឹងទាស់ក៏ដោយក៏ពិរុទ្ធជននោះ នៅតែនៅក្នុងឃុំដោយគ្មានគោលការណ៍និរន្តភាពនៃដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់តុលាការ ប៉ុន្តែពិរុទ្ធជនដែលបានប្តឹងទាស់នោះអាចធ្វើពាក្យសុំនៅក្រៅឃុំទៅតុលាការ ក្នុងករណីនេះតុលាការនៅតែមានសមត្ថកិច្ចដើម្បីសម្រេចអំពីការដោះលែងជនជាប់ចោទឲ្យមានសេរីភាពវិញ[17]។ តើតុលាការនឹងសម្រេចយ៉ាងដូចម្តេចនៅពេលដែលមានពាក្យសុំនៅក្រៅឃុំរបស់ជនជាប់ចោទ? ក្នុងករណី ដែលមានពាក្យសុំនៅក្រៅឃុំរបស់ជនជាប់ចោទនោះតុលាការនឹងពិចារណា និងសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១០ថ្ងៃក្រោយទទួលពាក្យសុំនោះ[18]។ ក្នុងករណី ដែលតុលាការយល់ព្រមដោះលែងជនជាប់ចោទឲ្យមានសេរីភាពនោះ ជននោះនៅតែរក្សាការឃុំខ្លួនរហូតទាល់តែផុតរយៈពេលបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា[19] ដែលមានរយៈពេល៤៨ម៉ោង គិតចាប់ពីថ្ងៃសម្រេចដោះលែង[20] លើកលែងតែព្រះរាជអាជ្ញាយល់ព្រមភ្លាមៗ នៅពេលដែលតុលាការចេញសេចក្តីសម្រេចឲ្យដោះលែង។

[17] មាត្រា ៣៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[18] មាត្រា ៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[19] មាត្រា ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[20] មាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ផ្នែកទី២៖ បណ្តឹងឧទ្ធរណ៍ទៅលើសាលក្រមព្រហ្មទណ្ឌ

## ១.និយមន័យ

បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ គឺជាបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់ មានន័យថា ប្តឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ច ដើម្បីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ដែលធ្វើប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួននៅក្នុងរឿងព្រហ្មទណ្ឌ។ មានន័យថា ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមចុងក្រោយនៃការជំនុំជម្រះរបស់សាលាដំបូងដែលទាមទារឲ្យ សាលាឧទ្ធរណ៍វិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រមរបស់សាលាដំបូង។ បើបុគ្គលណាមួយ ដែលមិនសុខចិត្តទៅនឹងសេចក្តីសម្រេចនោះ អាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បានមុនពេលដែល សាលក្រមនោះចូលជាស្ថាពរ ប្រសិនបើសាលក្រមចូលស្ថាពរមិនអាចប្តឹងឧទ្ធរណ៍បានឡើយ។

## ២.សាលក្រមដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បាន

នាពេលដែលចៅក្រមជំនុំជម្រះ ធ្វើការសម្រេចក្តីរួចហើយ សេចក្តីសម្រេចនោះបើភាគីមិនសុខចិត្តអាចធ្វើការប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចនោះបាន។ ទោះយ៉ាងណាក៏ដោយ សេចក្តីសម្រេចរបស់ចៅក្រមជំនុំជម្រះមិនអាចធ្វើការប្តឹងឧទ្ធរណ៍បានស្រេចតែចិត្តនោះទេ ហើយចំពោះសាលក្រមដែលអាចប្តឹងឧទ្ធរណ៍បានមានដូចជា៖ សាលក្រមក្នុងរឿងឃុំខ្លួន, សាលក្រមចាត់របៀប, សាលក្រមអង្គសេចក្តី។

### ២.១.សាលក្រមក្នុងរឿងឃុំខ្លួន

នាពេលដែលជនជាប់ចោទបានចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូង ដោយជននោះជានីតិជន ហើយជននោះទៀតសោត បានប្រព្រឹត្តបទល្មើសជាក់ស្តែង ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ ចំណែកឯសំណុំរឿងវិញមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបាន។

តុលាការបើកសវនាការ នាថ្ងៃដែលជនជាប់ចោទចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូង ក្នុងថ្ងៃនោះតែម្តង។ បន្ទាប់ពីបាន បើកសវនាការនិងធ្វើការពិភាក្សាដេញដោលចប់សព្វគ្រប់ហើយ តុលាការនឹងធ្វើការប្រកាសសាលក្រម ហើយសាលក្រមនោះហៅថា សាលក្រមឃុំខ្លួន។

សាលក្រមឃុំខ្លួន ជាសាលក្រមដែលសម្រេចអំពីការឃុំខ្លួន ឬមិនឃុំខ្លួនបណ្តោះអាសន្ន ឬសម្រេចអំពីការដោះលែងឱ្យមានសេរីភាព ឬមិនដោះលែងឱ្យមានសេរីភាព។

តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន តាមសាលក្រមដែលមានសំអាងហេតុ។[21] តុលាការត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន។

សាលក្រមត្រូវអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេល ដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃនៃការចូលទៅបង្ហាញខ្លួនលើកមុខតុលាការ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ចប់ដោយពេញលក្ខណៈច្បាប់ក្រោយពីការផុតរយៈពេល ០២ (ពីរ) សប្តាហ៍។

ប្រសិនបើ តុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌ មិនបានបំពេញទេ ឬ ក៏ដោយភាពសាំញ៉ាំនៃរឿងទាមទារជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកធ្វើការស៊ើបសួរ។[22] ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង[23]។

នៅគ្រប់ពេលវេលា តុលាការអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទដែលជាប់ឃុំ ឱ្យមានសេរីភាពវិញបាន ឬ ឱ្យបន្តការឃុំខ្លួនជនជាប់ចោទដោយយោងតាមមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ។

តុលាការអាចសម្រេចក្រោយពីបានស្តាប់ជនជាប់ចោទ មេធាវី និងព្រះរាជអាជ្ញា[24]។

ជនជាប់ចោទដែលត្រូវបានឃុំខ្លួន អាចសុំដល់តុលាការឱ្យដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយផ្ទាល់មាត់នៅពេលសវនាការ ឬ តាមលិខិតដែលធ្វើជូនទៅក្រឡាបញ្ជី។

ពាក្យសុំដោះលែងនៅក្រៅឃុំ អាចធ្វើដោយមេធាវីរបស់ជនជាប់ចោទដែលត្រូវបានឃុំខ្លួនដោយផ្ទាល់មាត់នៅពេលសវនាការ។

កាលណាពាក្យសុំបានឆ្លើយដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃសវនាការ។ កាលណាពាក្យសុំបានធ្វើតាមលិខិត ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទទទួលនៅលើលិខិតនេះ ហើយបញ្ជូនជាបន្ទាន់ទៅដល់ប្រធានតុលាការ។

[21] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[22] មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[23] មាត្រា ៣០៤ កថាខណ្ឌ ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[24] មាត្រា ៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

តុលាការសម្រេច ក្រោយពីបានស្តាប់ជនជាប់ចោទ មេធាវី និងព្រះរាជអាជ្ញា។ តុលាការត្រូវសម្រេចនៅក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល១០ថ្ងៃ ក្រោយពីការសុំដោយផ្ទាល់មាត់ ឬ ក្រោយពីទទួលពាក្យសុំដែលធ្វើជាលាយលក្ខណ៍អក្សរ[25]។

## ២.២. សាលក្រមចាត់របៀប

សាលក្រម ដែលសម្រេចអំពីបញ្ហានីតិវិធី ហើយមិនជំនុំជម្រះដល់អង្គសេចក្តីនោះទេ នៅពេលលេចឡើងនូវអញ្ញាត្រកម្ម ឬអង្គហេតុថ្មី សាលក្រមនីតិវិធីបែបនេះហៅថា សាលក្រមចាត់របៀប[26]។

សាលក្រមចាត់របៀប ជាសាលក្រមដែលសម្រេចអំពីបញ្ហានីតិវិធី ឬ បង្គាប់អោយស៊ើបសួរបន្ថែម។

កាលណាតុលាការចេញសាលក្រមចាត់របៀប បណ្តឹងឧទ្ធរណ៍អាចត្រូវទទួលបានភ្លាម ប្រសិនបើសាលក្រមនេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យ បានលុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្តី[27]។

### ២.២.១.សាលក្រមដែលទាក់ទងនឹងសមត្ថកិច្ចសាលាដំបូង

នៅពេលដែលចៅក្រមជំនុំជម្រះទទួលសំណុំរឿងជំនុំជម្រះ ហើយនាថ្ងៃកាលបរិច្ឆេទសវនាការបានមកដល់ ហើយតុលាការធ្វើការពិភាក្សាដេញដោលជាសាធារណៈ ហើយបើតុលាការយល់ឃើញថាសំណុំរឿងជំនុំជម្រះនោះខុសសមត្ថកិច្ចរបស់ខ្លួន។ ដូចនេះ តុលាការចេញសាលក្រមចាត់របៀបទាក់ទងនឹងសមត្ថកិច្ចរបស់សាលាដំបូង។ ហើយចំពោះសំណុំរឿងនោះត្រូវទៅបង្វិលទៅសាលាដំបូងដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះវិញ។ ចំពោះសាលក្រមបែបនេះ ជាសាលក្រមចាត់របៀបបញ្ចប់នីតិវិធី ហើយអាចធ្វើការប្តឹងឧទ្ធរណ៍បាន[28]។

ចំពោះតុលាការដែលមានសមត្ថកិច្ចខាងដែនដីគឺៈ

- តុលាការនាទីកន្លែងបទល្មើស
- តុលាការនាលំនៅឋានរបស់ជនជាប់ចោទ ឬ
- តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ។

ក្នុងករណីដែលមានតុលាការពីរ ឬ ច្រើន ដែលស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួល

[25] មាត្រា ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[26] https://ciclg.com/kh/article/64
[27] មាត្រា ៣៨៥ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[28] មាត្រា ៣៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ពាក្យប្ដឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង។

វិវាទសមត្ថកិច្ចដែនដី រវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នាត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់។

ការសម្រេចនេះបិទផ្លូវតវ៉ា។

សមត្ថកិច្ចចំពោះជនជាប់ចោទត្រូវពន្លាតរហូតដល់សហចារី អ្នកផ្ដើមគំនិត និងអ្នកសមគំនិតទាំងអស់។

ប្រសិនបើ តុលាការដែលបានទទួលពាក្យប្ដឹងយល់ឃើញថា ពុំមានសមត្ថកិច្ចតាមដែនដីតុលាការនេះ ប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រម និងបង្គាប់ឱ្យបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះជូនតុលាការដែលមានសមត្ថកិច្ចតាមដែនដី។ ជាយថាហេតុ តុលាការនេះសម្រេចសេចក្ដីលើការបន្តដាក់ជនជាប់ចោទឱ្យស្ថិតនៅក្នុងការឃុំខ្លួន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ[29]។

### ២.២.២.សាលក្រមពិភាក្សាដេញដោលជាសម្ងាត់

ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ។

ប៉ុន្តែ បើតុលាការយល់ឃើញថាសាធារណៈភាព បង្កឱ្យមានគ្រោះថ្នាក់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទំលាប់នោះតុលាការតាមសេចក្ដីសម្រេចមានសំអាងហេតុ អាចបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលទាំងស្រុង ឬ មួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់។ តុលាការសម្រេចតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្ដី ឬ តាមសេចក្ដីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្ដី។

សេចក្ដីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់ មិនអាចតវ៉ាបានទេ[30]។

### ២.២.៣.សាលក្រមដែលបង្គាប់ធ្វើការស៊ើបសួរបន្ថែម

សំណុំរឿងដែលយកមកជំនុំជម្រះ សំណុំរឿងនោះគឺជាសំណុំរឿងដែលមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើចៅក្រមជំនុំជម្រះយល់ឃើញថា ត្រូវធ្វើការស៊ើបសួរបន្ថែម ស្រាវជ្រាវរកភស្តុតាងថ្មីជាចាំបាច់ ចៅក្រមជំនុំជម្រះអាចបង្គាប់តាមសាលក្រមចាត់របៀប ដើម្បីឱ្យចៅក្រមជំនុំជម្រះធ្វើការស៊ើបសួរបន្ថែម។

នៅពេលសំណុំរឿងបានបញ្ចប់ការស៊ើបសួររួចរាល់ហើយ ហើយបានបញ្ជូនសំណុំរឿងនោះទៅចៅក្រមជំនុំជម្រះ ហើយនាពេលជំនុំជម្រះចៅក្រមជំនុំជម្រះយល់ឃើញថា ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមថ្មី។ ចៅក្រម

[29] មាត្រា ២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[30] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ជំនុំជម្រះចេញសាលក្រមចាត់របៀបបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែម[31]។

អ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមនេះគឺៈ

- ប្រធានសវនាការ
- ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ កាលណាតុលាការសម្រេចជាក្រុមសមូហភាព
- ចៅក្រមដទៃទៀត នៃតុលាការជាន់ដំបូង

សាលក្រមដែលបង្គាប់ធ្វើការស៊ើបសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឱ្យទទួលភារកិច្ចនេះ។

នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រមនេះអាចៈ

- ចុះទៅលើគ្រប់វិសាលភាពនៃដែនសមត្ថកិច្ចតុលាការ ឬ លើគ្រប់វិសាលភាពនៃដែនដីជាតិ
- ស្តាប់ចម្លើយសាក្សី
- ធ្វើការឆែកឆេរ
- ចាប់យកវត្ថុតាង
- បង្គាប់ឱ្យធ្វើកោសលវិច័យ។

ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ[32]។

### ២.២.៤.សាលក្រមជំនុំជម្រះលើរឿងអញ្ញត្រកម្ម

នៅពេលដែលមានភាគីលើកឡើងអំពីអញ្ញត្រកម្មមុនដំណាក់កាលការពារដល់អង្គសេចក្តី[33] តុលាការដែលទទួលបណ្តឹងអាជ្ញាមានសមត្ថកិច្ច ដើម្បីសម្រេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ ដែលលើកឡើងដោយគូភាគី[34]។

តុលាការត្រូវសម្រេចអំពីអញ្ញត្រកម្ម តាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមនៃអង្គសេចក្តី។

ប៉ុន្តែ តុលាការក៏អាចបញ្ចូលឧបឬត្តិហេតុទៅនឹងអង្គសេចក្តី ហើយសម្រេចតាមសាលក្រមតែមួយដូចគ្នាអំពីអញ្ញត្រកម្មជាមួយនឹងអង្គសេចក្តី[35]។

---

[31] កថាខណ្ឌ ៣ មាត្រា ៣៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[32] មាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[33] មាត្រា ៣៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[34] មាត្រា ៣៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[35] មាត្រា ៣៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

## ៣.សាលក្រមអង្គសេចក្តី

សាលក្រមអង្គសេចក្តី ជាសាលក្រមដែលសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើស និងបញ្ហាពាក់ព័ន្ធនឹងរឿងក្តី[36]។ សាលក្រមអង្គសេចក្តីមាន៖ សាលក្រមចំពោះមុខ[37] សាលក្រមចាត់ទុកថាចំពោះមុខ[38] និងសាលក្រមកំបាំងមុខ[39]។

### ៣.១. សាលក្រមចំពោះមុខ

សាលក្រមចំពោះមុខ គឺជាសាលក្រមទាំងឡាយណាដែលចេញនៅពេលសវនាការជំនុំជម្រះ ដែលភាគី ឬ ចាត់ទុកថាភាគីវត្តមាន។

សាលក្រមនេះអាចចេញទៅលើជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

#### ៣.១.១.សាលក្រមចំពោះមុខជនជាប់ចោទ

ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ ឬទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ ឬ ជនជាប់ចោទមានមូលហេតុស្ថានភាពសុខភាព ឬ ដោយមូលហេតុធ្ងន់ធ្ងរ ដែលធ្វើឱ្យជនជាប់ចោទ មិនអាចចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការបានទេ ប្រធានសវនាការអាចបង្គាប់ឱ្យសួរជនជាប់ចោទ នៅកន្លែងដែលជននោះនៅ[40] ហើយសាលក្រមនោះជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមនេះមិនបាច់ជូនដំណឹងដល់ជនជាប់ចោទទេ។ សាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន[41]។

#### ៣.១.២.សាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅពេលសវនាការ ឬ មានអ្នកតំណាងដោយត្រឹមត្រូវនោះ សាលក្រមត្រូវជាសាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីនេះ។ សាលក្រមនេះមិនត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ សាលក្រមនេះអាចត្រូវប្តឹងឧទ្ធរណ៍បាន[42]។

#### ៣.១.៣.សាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ប្រសិនបើ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីបានបង្ហាញខ្លួននៅពេលសវនាការជំនុំជម្រះ ឬ ត្រូវបានអ្នក

---

[36] គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ លោក **សេង នាង** មេរៀនស្តីពី **បច្ចេកទេសតាក់តែងសាលក្រមព្រហ្មទណ្ឌ**។

[37] មាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[38] មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[39] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[40] មាត្រា ៣០៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[41] មាត្រា ៣៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[42] មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

តំណាងបង្ហាញខ្លួនជំនួសនោះ សាលក្រមជាសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមនេះមិនត្រូវជូនដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ។ សាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន[43]។

### ៣.២. សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ បានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។

សាលក្រមដែលត្រូវចាត់ទុកចំពោះមុខនេះ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមនេះអាចប្តឹងឧទ្ធរណ៍។

ក្នុងករណីដែលជនជាប់ចោទអវត្តមាន បានបង្ហាញមូលហេតុអំពីការអវត្តមានរបស់ខ្លួនហើយតុលាការក៏បានទទួលថាត្រឹមត្រូវ នោះតុលាការអាចលើករឿងទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀត[44]។

### ៣.៣.សាលក្រមកំបាំងមុខ

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។

សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទនេះ។ សាលក្រមនេះអាចត្រូវប្តឹងទាស់បាន[45]។

## ៤.បុគ្គលដែលអាចប្តឹងឧទ្ធរណ៍បាន

បុគ្គលដែលអាចប្តឹងឧទ្ធរណ៍បានមានដូចជា ព្រះរាជាអាជ្ញានៃតុលាការជាន់ដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ( ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី )[46]។

[43] មាត្រា ៣៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[44] មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[45] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[46] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

## ៤.១.បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ជាម្ចាស់នៃបណ្តឹងអាជ្ញា ដែលអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅនឹងសាលក្រម របស់តុលាការជាន់ដំបូង។ ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចដែនដី អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចតែ ផ្នែកព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធផ្នែករដ្ឋប្បវេណីទេ ព្រោះអយ្យការតំណាងឲ្យសាធារណៈ មិនតំណាងឲ្យប្រយោជន៍ឯកជនទេ។ ទោះបីតំណាងអយ្យការ ជាអ្នករក្សាការពារប្រយោជន៍សាធារណៈក៏ដោយ ក៏សកម្មភាពរបស់អយ្យការត្រូវបានកម្រិត ហើយរាល់សកម្មភាពទាំងឡាយត្រូវអនុវត្តទៅ តាមនីតិវិធីច្បាប់ផងដែរ។

## ៤.២. បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

អគ្គព្រះរាជអាជ្ញា គឺជាអ្នកតំណាងនៃអង្គការអយ្យការអមសាលាឧទ្ធរណ៍[47]។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអ្នកឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដី នៃសាលាឧទ្ធរណ៍ មានន័យថា អគ្គព្រះរាជអាជ្ញា ជាអ្នកដើរតួរយ៉ាងសំខាន់មួយរូប ក្នុងនាមជាអ្នកការពារផលប្រយោជន៍សាធារណៈ និងការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌ ភាពត្រឹមត្រូវ ដោយធានាឲ្យបាននូវសមមូល ក្នុងការអនុវត្តច្បាប់ជាធរមាន។

## ៤.៣. បណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន

ពិរុទ្ធជន អាចធ្វើបណ្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមរបស់តុលាការជាន់ដំបូង ដោយត្រូវគោរពទៅតាមនីតិវិធី ឬរបៀបនៃការប្តឹងដែលអាចទទួលយកបាន និងត្រូវគោរពទៅតាម ពេលវេលាដែលត្រូវកំណត់ដោយច្បាប់ផងដែរ។

ក្នុងរយៈពេលបណ្តឹងឧទ្ធរណ៍ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែ ជនជាប់ចោទដែលត្រូវបានជាប់ឃុំ ដែលបានចូលបង្ហាញខ្លួននៅចំពោះមុខ តុលាការជាន់ដំបូងត្រូវនៅក្នុងពន្ធនាគារ រហូតដល់សាលាឧទ្ធរណ៍ធ្វើការសម្រេចសេចក្តីចប់។

ក្នុងករណីដែលតុលាការជាន់ដំបូងសម្រេចឲ្យរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាង ឬស្មើនឹងរយៈពេល នៃការឃុំខ្លួនបណ្តោះអាសន្នព្រះរាជអាជ្ញា អាចយល់ព្រមដោះលែង ជនជាប់ចោទឲ្យមានសេរីភាព មុនផុតកំណត់រយៈពេលសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍[48]។

## ៤.៤. បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី

[47] មាត្រា ៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[48] មាត្រា ៣៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍បាន ដែលបណ្តឹងនោះត្រូវធ្វើតាមទម្រង់ និងរយៈពេលកំណត់ដោយច្បាប់។ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍បានចំពោះតែផលប្រយោជន៍ខាងរដ្ឋប្បវេណីប៉ុណ្ណោះ[49]។

ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានតំណាងដោយ មេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដែលអ្នកទាំងនេះត្រូវមានលិខិតប្រគល់សិទ្ធិឲ្យបណ្តឹងឧទ្ធរណ៍[50]។ លិខិតប្រគល់សិទ្ធិត្រូវតែមានចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកប្តឹង ឬអ្នកតំណាងរួមជាមួយនឹងក្រឡាបញ្ជី[51]។

## ៥.រយៈពេលសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍

### ៥.១. រយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម[52]។

ក្នុងករណីដែលតុលាការបាន សម្រេចផ្តន្ទាទោសជននោះ តិចពេកមិនសមមូលទៅនឹងការកំណត់ច្បាប់ជាធរមាន ព្រះរាជអាជ្ញាជាអ្នកដើរតួក្នុងការប្តឹងឧទ្ធរណ៍។

ក្នុងករណី មានបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ ព្រះរាជអាជ្ញាមានរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ ក្នុងករណីភាគីដទៃទៀតបានធ្វើបណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេលខាងលើ។ រយៈពេលបន្ថែមគិតចាប់ពីការផុតរយៈពេលធម្មតា[53]។

ក្នុងករណី មានការឃុំខ្លួនពិរុទ្ធជនមានរយៈពេលប្តឹងឧទ្ធរណ៍ចំនួន ៤៨ (សែសិបប្រាំបី) ម៉ោង ផ្តើមគិតពីពេលតុលាការសម្រេចពីការឃុំខ្លួន[54]។

### ៥.២. រយៈពេលបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីពេលប្រកាសសាលក្រម[55]។ ក្នុងករណី ដែលតុលាការបានសម្រេចការផ្តន្ទាទោសជននោះ តិចពេកមិនសមមូលទៅការកំណត់របស់ច្បាប់ជាធរមាន អគ្គព្រះរាជអាជ្ញាដើរតួក្នុងការប្តឹងឧទ្ធរណ៍។

---

[49] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[50] វាក្យខ័ណ្ឌទី១ និងទី៣ មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[51] វាក្យខ័ណ្ឌទី៣ មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[52] កថាខណ្ឌទី ១ មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[53] មាត្រា ៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[54] មាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[55] កថាខណ្ឌទី ២ មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### ៥.៣. រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន

បណ្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជនត្រូវធ្វើក្នុងរយៈពេល ០១ (មួយ) ខែ។ កាលណា សាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលបណ្ដឹងឧទ្ធរណ៍គិតចាប់ពីពេល ប្រកាសសាលក្រម។ ដោយឡែក សាលក្រមចាត់ទុកជាចំពោះមុខ រយៈបណ្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះ ធ្វើតាមវិធីណាក៏ដោយ[56]។

ក្នុងករណីបណ្ដឹងឧទ្ធរណ៍ឧប្បត្តិហេតុ ពិរុទ្ធជនមានរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្ដឹងឧទ្ធរណ៍ឧប្បត្តិហេតុ ក្នុងករណីភាគីដទៃទៀតបានធ្វើបណ្ដឹងឧទ្ធរណ៍ ក្នុងរយៈពេលខាងលើ។ រយៈពេលបន្ថែមគិតចាប់ពីការផុតរយៈពេលធម្មតា[57]។

ក្នុងករណីមានការឃុំខ្លួនពិរុទ្ធជនមានរយៈពេលប្ដឹងឧទ្ធរណ៍ចំនួន ៥ (ប្រាំ) ថ្ងៃ ផ្ដើមគិតពីពេលតុលាការសម្រេចពីការឃុំខ្លួន[58]។

### ៥.៤. រយៈពេលបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី

បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវធ្វើក្នុងរយៈពេល ០១ (មួយ) ខែ។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលបណ្ដឹងឧទ្ធរណ៍ ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម។ ដោយឡែកសាលក្រមចាត់ទុកចំពោះមុខ រយៈពេលបណ្ដឹងឧទ្ធរណ៍ ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះតាមវិធីណាក៏ដោយ[59]។

## ៦.អានុភាពនៃបណ្ដឹងឧទ្ធរណ៍

### ៦.១. អានុភាពនៃបណ្ដឹងឧទ្ធរណ៍នៅលើការអនុវត្តសាលក្រម

នៅក្នុងរយៈពេលប្ដឹងឧទ្ធរណ៍ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែ ជនជាប់ចោទ ដែលជាប់ឃុំ ដែលបានចូលខ្លួននៅមុខតុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារ នៅក្នុងរយៈពេលសម្រាប់ប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចខាងសំណុំរឿងព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុង ពន្ធនាគារដល់ការសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍ តាមរយៈសាលដីកា។

ក្នុងករណី ដែលតុលាការជាន់ដំបូងបានសម្រេចអោយរួចខ្លួន បានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ព្រះរាជអាជ្ញា អាចយល់ព្រមឲ្យមានការដោះលែងជន

[56] មាត្រា ៣៨២ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[57] មាត្រា ៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[58] មាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[59] មាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ជាប់ចោទឱ្យមានសេរីភាពវិញបាន មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ រយៈពេលប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ[60]។

## ៦.២. អានុភាពនៃបណ្តឹងឧទ្ធរណ៍លើជនជាប់ចោទ

សាលាឧទ្ធរណ៍ កាលណាបានទទួលពាក្យបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ សាលាឧទ្ធរណ៍មិនអាចដាក់ទម្ងន់ទោសលើជននោះបានទេ។ តុលាការអាចកែប្រែសាលក្រមបាន នៅក្នុងន័យដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ។ សាលាឧទ្ធរណ៍មិនអាចបន្ថែម ទោសពីលើ មូលទោស បានទេ។

សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើស ដែលបានកំណត់ ដោយតុលាការ ជាន់ដំបូង ដោយឈ្មោះបទល្មើសមួយទៀតបាន ប៉ុន្តែមិនអាចដាក់បន្ថែមទម្ងន់ទោស លើជនជាប់ចោទនេះបានទេ។

ប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយ ដែលដាច់ខាតត្រូវតែប្រកាសនោះសាលាឧទ្ធរណ៍អាចបដិសេធសាលក្រម ហើយសម្រេចអំពីទោសជាថ្មីម្តងទៀត។ កាលណាបានទទួលបណ្តឹងតែពីជនជាប់ចោទប៉ុណ្ណោះ សាលាឧទ្ធរណ៍ មិនអាចបន្ថែម ចំនួនទឹកប្រាក់សម្រាប់ជួសជុលខូចខាត ដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ[61]។

## ៦.៣. អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញានាំឲ្យសើរើឡើងវិញ នូវសេចក្តីសម្រេចខាង ព្រហ្មទណ្ឌនៃតុលាការជាន់ដំបូង។ សាលាឧទ្ធរណ៍ជាយថាហេតុ អាចបដិសេធ សាលក្រមដែលនាំឲ្យរួចខ្លួន ឬអាចសម្រេចឲ្យជនជាប់ចោទរួចខ្លួនជានិច្ច ប្រសិនបើ យល់ឃើញថាមានពិរុទ្ធភាពលើជននេះមិនអាចបង្ហាញអោយឃើញទេ។

សាលាឧទ្ធរណ៍ អាចប្រកាសទោសបន្ថែម ដែលដាច់ខាតត្រូវតែប្រកាសដោយខានតែបាន ដែលតុលាការជាន់ដំបូងភ្លេចមិនបានប្រកាស។

## ៦.៤. អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា នាំឲ្យសើរើឡើងវិញ នូវសេចក្តីសម្រេច ខាងសំណុំរឿងព្រហ្មទណ្ឌនៃតុលាការជាន់ដំបូង។ សាលាឧទ្ធរណ៍ជាយថាហេតុ អាចបដិសេធសាលក្រម ដែលនាំឲ្យរួចខ្លួន ឬអាចសម្រេចឲ្យជនជាប់ចោទរួចខ្លួនជានិច្ច ប្រសិនបើយល់ឃើញថា មានពិរុទ្ធភាពលើជននេះមិនអាចបង្ហាញអោយឃើញទេ។

[60] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[61] មាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

សាលាឧទ្ធរណ៍អាចប្រកាសទោសបន្ថែម ដែលដាច់ខាតត្រូវតែប្រកាសដោយខានមិនបាន ដែលតុលាការជាន់ទាបភ្លេចមិនបានប្រកាស។[62]

## ៦.៥.អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបានតែលើផលប្រយោជន៍ ផ្នែករដ្ឋប្បវេណី ប៉ុណ្ណោះ។ នៅមុខសាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើពាក្យប្តឹងសុំថ្មី ដែលមិនបានដាក់ជូនតុលាការពិនិត្យនោះទេ។[63]

## ៦.៦.បណ្តឹងឧទ្ធរណ៍ដែលមិនអាចទទួលយកបាន

កាលណាសាលាឧទ្ធរណ៍យល់ឃើញថា បណ្តឹងឧទ្ធរណ៍ធ្វើហួសពេលកំណត់ឬធ្វើនៅក្នុងលក្ខខណ្ឌមិនត្រឹមត្រូវនោះ សាលាឧទ្ធរណ៍ប្រកាសថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។[64]

## ៦.៧. ការបដិសេធសាលក្រម

សាលាឧទ្ធរណ៍យល់ឃើញថា គ្មានពិរុទ្ធភាពលើជនជាប់ចោទទេ ឬក៏អំពើនោះ មិនមែនជាបទល្មើសទេ សាលាឧទ្ធរណ៍បដិសេធសាលក្រម ហើយអោយជនជាប់ចោទ រួចខ្លួន។[65]

កាលណាសាលាឧទ្ធរណ៍ពិនិត្យ មើលឃើញថា សាលក្រមរបស់តុលាការជាន់ដំបូង មានជាប់មោឃភាព សាលាឧទ្ធរណ៍ អាចសម្រេចលើអង្គសេចក្តីឡើងវិញដូចតុលាការ ជាន់ដំបូងដែរ។[66]

---

[62] មាត្រា ៤០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[63] មាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[64] មាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[65] មាត្រា ៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[66] មាត្រា ៤០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ជំពូកទី២

# ការអនុវត្តនីតិវិធីនៃការធ្វើបណ្ដឹងទាស់ និងបណ្ដឹងឧទ្ធរណ៍

## ផ្នែកទី១៖ នីតិវិធីនៃការធ្វើបណ្ដឹងទាស់

នាពេលដែលចៅក្រមស៊ើបសួរ បានបញ្ចប់ការស៊ើបសួររួចរាល់ហើយ ហើយបញ្ជូនសំណុំរឿងទៅកាន់ប្រធានសាលាដំបូងដើម្បីធ្វើការបែងចែកសំណុំរឿង។ ចំពោះសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះ ចៅក្រមជំនុំជម្រះទទួលបណ្ដឹងដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ, ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា, កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា[67]។

បន្ទាប់ពី ធ្វើការបែងចែកសំណុំរឿងរួចរាល់ហើយ ហើយចៅក្រមជំនុំជម្រះទទួលបាននូវសំណុំរឿងជំនុំជម្រះ។ ប្រធានតុលាការ ធ្វើការកំណត់កាលបរិច្ឆេទសវនាការ ក្នុងករណីបានទទួលបណ្ដឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលនៃការកោះហៅ ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ[68] ដើម្បីធ្វើការជំនុំជម្រះ ហើយធ្វើដីកាបញ្ជូនសំណុំរឿងជំនុំជម្រះទៅព្រះរាជអាជ្ញា ដើម្បីអោយព្រះរាជអាជ្ញាធ្វើការកោះហៅភាគីចូលរួមសវនាការ ដូចជា កោះហៅជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី លិខិតអញ្ជើញមេធាវី និងភ្ជាប់ជាមួយនឹងដីកាបញ្ជូន។

នាថ្ងៃកាលបរិច្ឆេទសវនាការបានមកដល់ ហើយភាគីមិនបានចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខភាគីដែលអវត្តមាន។ ហើយសាលក្រមកំបាំងមុខ ត្រូវជូនដំណឹងដល់ជនដែលអវត្តមាន សាលក្រមកំបាំងមុខអាចធ្វើបណ្ដឹងទាស់បាន។

## ១.នីតិវិធីមុនពេលដាក់ពាក្យបណ្ដឹង

### ១.១.ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ

នៅពេលដែលតុលាការធ្វើការប្រកាសសាលក្រមកំបាំងមុខរួចហើយ ត្រូវធ្វើការជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធ។ ចំពោះការជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធអាចត្រូវធ្វើដោយព្រះរាជអាជ្ញា។ ក្រឡាបញ្ជីអយ្យការ ធ្វើ

[67] មាត្រា ២៩១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[68] មាត្រា ២៩២ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ការជូនដំណឹងអំពីសាលក្រមកំបាំងមុខ ដោយបញ្ជូនលិខិតនោះទៅសមត្ថកិច្ចជំនាញ អាចជាមន្ត្រីនគរបាល កងរាជអាវុធហត្ថ ឬ មន្ត្រីជំនាញផ្សេងៗ ដើម្បីឱ្យធ្វើការបញ្ជូនលិខិតជូនដំណឹង ឬ ក្រឡាបញ្ជី ជាអ្នកទទួលបន្ទុកក្នុងការបញ្ជូនលិខិតជូនដំណឹងទៅឱ្យជនទាំងនោះ ដើម្បីឱ្យបានដឹងពីសេចក្ដីសម្រេចរបស់តុលាការ។ ការជូនដំណឹងក៏អាចត្រូវធ្វើដោយអាជ្ញាសាលាផងដែរ។

នៅពេលដែលភាគី បានទទួលនូវសេចក្ដីសម្រេចហើយត្រូវធ្វើការផ្ដិតស្នាមម្រាមដៃទទួល ឬ ចុះហត្ថលេខា ឬ មិនព្រមផ្ដិតម្រាមដៃទេ ឬ ចុះហត្ថលេខានោះទេ ត្រូវចារនៅលើលិខិតនោះថាមិនព្រមផ្ដិតស្នាមម្រាមដៃ ឬ ចុះហត្ថលេខាទទួលនោះទេ ហើយត្រូវបង្វិលឯកសារនោះទៅតុលាការវិញដើម្បីទុកជាភស្តុតាង។

### ១.១.១.ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការដោយព្រះរាជអាជ្ញា

យើងដឹងហើយថា អង្គការអយ្យការជានាវ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ[69] ដូចនេះការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការក៏ត្រូវបានអនុវត្តដោយព្រះរាជអាជ្ញាផងដែរ។

ការជូនដំណឹងដល់ភាគីពាក់ព័ន្ធអាចត្រូវធ្វើដោយព្រះរាជអាជ្ញា។

ក្នុងករណីនេះ ព្រះរាជអាជ្ញាប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចរបស់តុលាការឱ្យដល់ភាគីពាក់ព័ន្ធ។

ព្រះរាជអាជ្ញាចុះនិទ្ទេសលើសេចក្ដីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើមនេះ[70]។

### ១.១.២.ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការដោយអាជ្ញាសាលា

ការជូនដំណឹងក៏អាចត្រូវធ្វើដោយអាជ្ញាសាលាផងដែរ។

អាជ្ញាសាលាប្រើគ្រប់មធ្យោបាយ ដើម្បីជូនដំណឹងដល់បុគ្គលពាក់ព័ន្ធអំពីសេចក្ដីសម្រេចរបស់តុលាការ[71]។

## ១.២.ការចាប់ខ្លួនជនជាប់ចោទ

នាថ្ងៃកំណត់កាលបរិច្ឆេទសវនាការបានមកដល់ ការប្រកាសសាលក្រម បានចប់រួចរាល់ហើយ ហើយជនជាប់ចោទអវត្តមានមិនបានចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីដីកាកោះហៅនោះទេ នោះសាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។

ប្រសិនបើ តុលាការធ្វើការផ្ដន្ទាទោសដាក់ពន្ធនាគារ ០១ (មួយ) ឆ្នាំ យ៉ាងតិចដោយគ្មានការព្យួរទោស តុលាការតាមសម្រេចពិសេស និងដោយមានសំអាងហេតុ អាចចេញនៅក្នុងពេលសវនាការៈ

[69] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[70] មាត្រា ៤៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[71] មាត្រា ៤៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

- ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន
- ដីកាបង្គាប់ឱ្យចាប់ខ្លួនជនដែលអវត្តមាន

ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន មានអានុភាពអនុវត្តភ្លាមៗ។

ដីកាទាំងនោះមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណរបស់ពិរុទ្ធជន
- ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃការផ្តន្ទាទោសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកានេះត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនេះ និងបោះត្រាផង។

ពិរុទ្ធជនដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ត្រូវតែបានគេនាំទៅបង្ហាញខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុតនៅមុខព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួនដែលឱ្យដំណឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួន។

កាលណាសាលក្រមត្រូវបានសម្រេចដោយកំបាំងមុខនោះ ពិរុទ្ធជនដែលសម្រេចចិត្តថាប្តឹងទាស់ ត្រូវតែបង្ហាញខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខតុលាការដែលបានប្រកាសសាលក្រម។ ពិរុទ្ធជនអាចធ្វើពាក្យសុំនៅក្រៅឃុំ[72]។

នៅពេលចាប់ពិរុទ្ធជនបានហើយ ត្រូវនាំជននោះទៅបង្ហាញខ្លួននៅមុខព្រះរាជអាជ្ញានាទីកន្លែងដែលចាប់ខ្លួនបាន។ បន្ទាប់មកព្រះរាជអាជ្ញាធ្វើការសួរចម្លើយជននោះ មុននឹងធ្វើការសួរចម្លើយទៀតសោត ព្រះរាជអាជ្ញាអោយក្រឡាបញ្ជីអាននូវសាលក្រមកំបាំងមុខអោយជននោះស្តាប់ ហើយព្រះរាជអាជ្ញាសួរជននោះថាទទួលយកនូវសេចក្តីសម្រេចនោះឬអត់ បើមិនទទួលយក (ធ្វើការប្រាប់អំពីសិទ្ធិប្តឹងនឹងសេចក្តីសម្រេចនោះ ដូចដែលមានចែងក្នុង ការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍) ការណ៍ទាំងនោះក្រឡាបញ្ជីសរសេរក្នុងកំណត់ហេតុសួរចម្លើយ ហើយកំណត់ហេតុនោះចាត់ទុកដូចជាពាក្យបណ្តឹង។

## ២.នីតិវិធីក្នុងពេលដាក់ពាក្យបណ្តឹងទាស់

### ២.១.ការដាក់ពាក្យបណ្តឹងទាស់

ចំពោះភាគីដែលពាក់ព័ន្ធ បន្ទាប់ពីបានទទួលនូវសាលក្រមកំបាំងមុខ ហើយភាគីទាំងនោះមិនសុខចិត្តអាចធ្វើការប្តឹងទាស់នឹងសេចក្តីសម្រេចនោះបាន។ ការដាក់ពាក្យបណ្តឹងទាស់អាចត្រូវធ្វើឡើងដោយ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

[72] មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ចំពោះទម្រង់នៃបណ្តឹងទាស់ ទៀតសោតអាចធ្វើឡើង ដោយផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សរ ហើយយកទៅដាក់នៅការិយាល័យរដ្ឋបាល ឬ ការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។

### ២.១.១.បណ្តឹងធ្វើឡើងជាលាយលក្ខណ៍អក្សរ

បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ត្រូវធ្វើដោយពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ដែលបានធ្វើឡើងដោយ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

### ២.១.២.បណ្តឹងធ្វើឡើងដោយផ្ទាល់មាត់

នៅពេលដែលជនជាប់ចោទត្រូវបានចាប់ខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន ជននោះត្រូវបានគេនាំទៅបង្ហាញខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុតនៅមុខព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួនបាន នាពេលមកដល់ព្រះរាជអាជ្ញាធ្វើការសួរជនជាប់ចោទ។ មុនពេលសួរ ក្រឡាបញ្ជីធ្វើការអានសាលក្រមកំបាំងមុខនោះអោយជនជាប់ចោទស្តាប់ ហើយសួរជនជាប់ចោទថាទទួលយកនូវសេចក្តីសម្រេចឬអត់ បើមិនទទួលទេធ្វើការប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍ ការណ៍ទាំងនោះក្រឡាបញ្ជីសរសេរក្នុងកំណត់ហេតុសួរចម្លើយហើយ កំណត់ហេតុសួរចម្លើយនោះចាត់ទុកដូចជា ការដាក់ពាក្យបណ្តឹង។ បន្ទាប់មក ក្រឡាបញ្ជីបញ្ជូនជននោះទៅអោយចៅក្រមជំនុំជម្រះដើម្បីធ្វើការឃុំខ្លួន និងធ្វើការជំនុំជម្រះជាថ្មី។

## ២.២.ការពិនិត្យពាក្យបណ្តឹងទាស់

នាពេលមានបណ្តឹងទាស់ចូលមកក្រឡាបញ្ជីនឹងធ្វើការពិនិត្យនូវទម្រង់ និងលក្ខខណ្ឌ សុពលភាពនៃបណ្តឹងទាស់ថាតើធ្វើឡើងត្រឹមត្រូវតាមនីតិវិធីច្បាប់ ឬ អត់ដូចជា ធ្វើបណ្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីបានទទួលនូវការជូនដំណឹងអំពីសាលក្រមកំបាំងមុខ មើលទៅលើកាលបរិច្ឆេទនៃការជូនដំណឹងអំពីសាលក្រមកំបាំងមុខ។ បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ ថ្ងៃ ដើម្បីអោយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ធ្វើការប្តឹងទាស់។ លើសពីនេះទៅទៀត ក្រឡាបញ្ជីត្រូវពិនិត្យទៅលើអត្តសញ្ញាណ និងចំណុចដែរសរសេរនៅក្នុងបណ្តឹងទាស់នោះ។

# ៣.នីតិវិធីក្រោយពេលទទួលបណ្តឹងទាស់

## ៣.១.ការកំណត់កម្មវិធីជំនុំជម្រះជាថ្មី

នៅពេលដែលភាគីបានដាក់បណ្តឹងទាស់ហើយ ហើយបណ្តឹងទាស់នោះមានលក្ខណៈត្រឹមត្រូវដែលអាចទទួលយកបានហើយនោះ ចៅក្រមជំនុំជម្រះនឹងធ្វើការកំណត់កាលបរិច្ឆេទសវនាការថ្មី ដើម្បីកោះហៅភាគីដែលពាក់ព័ន្ធអោយមកចូលរួមសវនាការ និងធ្វើការពិភាក្សាដេញដោលជាថ្មី។

នៅពេលដែលធ្វើការកំណត់កម្មវិធីជំនុំជម្រះជាថ្មី ចៅក្រមជំនុំជម្រះធ្វើការកំណត់កាលបរិច្ឆេទសវនាការថ្មី អមជាមួយនឹងដីកាបញ្ជូនសំណុំរឿងទៅអយ្យការ ដើម្បីអោយព្រះរាជអាជ្ញាធ្វើការកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការ និងធ្វើដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលរួមសវនាការ (ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី)។

### ៣.១.១.រយៈពេលកំណត់ឱ្យចូលបង្ហាញខ្លួននាពេលសវនាការ

ក្នុងការកំណត់ឱ្យចូលបង្ហាញខ្លួននាពេលសវនាការ តុលាការត្រូវធ្វើការគិតគូរដល់ទីកន្លែងដែលជនជាប់ចោទរស់នៅ និងរយៈពេលនៃការប្រគល់ដីកាកោះហៅ។

ចំពោះរយៈពេលរវាងការប្រគល់ដីកាកោះហៅឱ្យជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅៈ

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ប៉ុន្តែ ក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួន គ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយរវាងការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ[73]។

### ៣.១.២.ការប្រគល់ដីកាកោះហៅដោយព្រះរាជអាជ្ញា

ដីកាកោះហៅអាចប្រគល់ឱ្យដល់ជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា។

ក្នុងករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះឱ្យដល់ជនជាប់ចោទ។ ព្រះរាជអាជ្ញាចុះហត្ថលេខានៅលើដើមដីកាកោះនេះ[74]។

### ៣.១.៣.របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅ

ចំពោះការប្រគល់ដីកាកោះទៀតសោត ក៏អាចត្រូវប្រគល់ឱ្យៈ

- ដោយក្រឡាបញ្ជី
- តាមផ្លូវរដ្ឋបាល
- ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំពីរឿងមួយផ្សេងទៀត
- តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។

[73] មាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[74] មាត្រា ៤៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថដែលព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះ ត្រូវតែគោរពតាមបញ្ជាព្រះរាជអាជ្ញា[75]។

### ៣.១.៤.ទម្រង់ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ

ទម្រង់នៃដីកាកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការ មាននិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃជនជាប់ចោទ
- កាលបរិច្ឆេទ និងទីកន្លែងកំណើតនៃជនជាប់ចោទ
- លំនៅឋាននៃជនជាប់ចោទ
- ការយោងដីកា ឬ សាលដីកាបញ្ជូន
- តុលាការដែលទទួលបណ្តឹងដើម្បីជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោង(វេលាម៉ោង)នៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចអមដោយមេធាវី។

### ៣.១.៥.ទម្រង់ដីកាកោះហៅដើមបណ្តឹងឱ្យចូលសវនាការ

ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលមកកាន់សវនាការមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី
- លំនៅឋានដើមបណ្តឹងរដ្ឋប្បវេណី
- ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកាកោះត្រូវបញ្ជាក់ បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី[76]។

### ៣.១.៦.ទម្រង់ដីកាកោះហៅជនរងគ្រោះឱ្យចូលសវនាការ

ដីកាកោះហៅជនរងគ្រោះឱ្យចូលមកកាន់សវនាការ កាលណាជននេះមិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅមុខចៅក្រមស៊ើបសួរទេ។ ដីកាកោះហៅនេះមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណជនរងគ្រោះ

[75] មាត្រា ៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[76] មាត្រា ៤៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

- លំនៅឋានជនរងគ្រោះ
- ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកាកោះហៅត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាជនរងគ្រោះ[77]។

### ៣.១.៧.ទម្រង់ដីកាកោះហៅសាក្សីឱ្យចូលសវនាការ

ដីកាកោះហៅសាក្សីឱ្យចូលមកកាន់សវនាការមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណសាក្សី
- លំនៅឋានសាក្សី
- ឈ្មោះជនជាប់ចោទ
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកាកោះហៅត្រូវបញ្ជាក់ថាៈ

- បុគ្គលដែលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាសាក្សី
- ការមិនចូលបង្ហាញខ្លួននៅពេលសវនាការ ការមិនព្រមឆ្លើយឱ្យព័ត៌មានក្នុងឋានៈជាសាក្សី ឬការឆ្លើយឱ្យព័ត៌មានក្លែងក្លាយត្រូវផ្តន្ទាទោសតាមច្បាប់[78]។

### ៣.១.៨.ទម្រង់ដីកាកោះហៅអ្នកជំនាញឱ្យចូលសវនាការ

ដីកាកោះហៅអ្នកជំនាញឱ្យចូលមកកាន់សវនាការមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណអ្នកជំនាញ
- លំនៅឋានអ្នកជំនាញ
- ឈ្មោះជនជាប់ចោទ
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

[77] មាត្រា ៤៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[78] មាត្រា ៤៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកាកោះហៅត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាអ្នកជំនាញ[79]។

### ៣.១.៩.ទម្រង់ដីកាកោះហៅអ្នកបកប្រែឱ្យចូលសវនាការ

ដីកាកោះហៅអ្នកបកប្រែឱ្យចូលមកកាន់សវនាការមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណអ្នកបកប្រែ
- លំនៅឋានអ្នកបកប្រែ
- ឈ្មោះជនជាប់ចោទ
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកាកោះហៅត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាអ្នកបកប្រែ[80]។

### ៣.១.១០.ទម្រង់ដីកាកោះហៅអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឱ្យចូលសវនាការ

ដីកាកោះហៅអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឱ្យចូលមកកាន់សវនាការមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- លំនៅឋានអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ឈ្មោះជនជាប់ចោទ
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដីកាកោះហៅត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[81]។

## ៣.២.ការសម្រេចលើបណ្តឹងទាស់

នាពេលដែលតុលាការធ្វើការពិនិត្យលើបណ្តឹងទាស់ ថាត្រឹមត្រូវតាមនីតិវិធីច្បាប់ហើយ តុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទសវនាការថ្មី។ នាថ្ងៃកាលបរិច្ឆេទសវនាការថ្មីបានមកដល់ សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅមុខតុលាការដដែល។

[79] មាត្រា ៤៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[80] មាត្រា ៤៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[81] មាត្រា ៤៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ភាគីទាំងអស់ត្រូវបានកោះហៅតាមគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា។

ក្រោយពីបានពិនិត្យមើលភាពអាចទទួលបាននៃបណ្តឹងទាស់នេះ តុលាការសម្រេចលើអង្គសេចក្តីជាថ្មីម្តងទៀត។

ប្រសិនបើអ្នកប្តឹងទាស់ដែលបានកោះហៅដោយត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ តុលាការប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ។ សាលក្រមដែលគេប្តឹងទាស់ មិនអាចត្រូវបានកែប្រែទេ។ សាលក្រមនេះមានអានុភាពទាំងស្រុងចំពោះភាគីទាំងអស់។ អ្នកប្តឹងទាស់នៅមានលទ្ធភាពប្តឹងឧទ្ធរណ៍[82]។

[82] មាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី២៖ នីតិវិធីនៃការធ្វើបណ្តឹងឧទ្ធរណ៍

ពេលដែលភាគីទទួលបានដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ហើយភាគីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការនោះទេ ភាគីអាចធ្វើការដាក់ប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល១ខែ។

## ១.ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

### ១.១.ការប្រកាសបណ្តឹងឧទ្ធរណ៍ដោយពិរុទ្ធជនដែលជាប់ឃុំ

បន្ទាប់ពី ប្រកាសសាលក្រមហើយ ពិរុទ្ធជនដែលនៅជាប់ឃុំមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការនោះ ពិរុទ្ធជននោះអាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍នៅមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ពិរុទ្ធជននេះបំពេញពាក្យប្តឹងឧទ្ធរណ៍ ដែលត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

ពាក្យប្តឹងឧទ្ធរណ៍ត្រូវចុះបញ្ជីដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួននៅលើបញ្ជីពិសេស។ ពិរុទ្ធជនចុះហត្ថលេខានៅរឹមនៃបញ្ជីនេះ។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវបញ្ជូនពាក្យប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលដ៏ខ្លីបំផុតទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យប្តឹងឧទ្ធរណ៍នេះ នៅលើបញ្ជីប្តឹងឧទ្ធរណ៍នៃតុលាការ[83]។

### ១.២.ទម្រង់នៃបណ្តឹងឧទ្ធរណ៍

#### ១.២.១.ទម្រង់នៃបណ្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

បណ្តឹងរបស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ចំពោះបណ្តឹងនោះទៀតសោត លុះត្រាតែបានធ្វើឡើងត្រឹមត្រូវតាមនីតិវិធីច្បាប់ ទើបតុលាការអាចទទួលយកបាន។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជន អាចតំណាងដោយឪពុក ម្តាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍នេះ។

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍នេះ។

---

[83] មាត្រា ៣៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេស ដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬអ្នកតំណាង។ លិខិតប្រគល់សិទ្ធិត្រូវភ្ជាប់នឹងលិខិតប្តឹងឧទ្ធរណ៍[84]។

### ១.២.២.ទម្រង់នៃបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

នាពេលដែល អគ្គព្រះរាជអាជ្ញាបានដឹងអំពីសាលក្រមរបស់សាលាដំបូង បើអគ្គព្រះរាជអាជ្ញាមិនសុខចិត្តនឹងសេចក្តីសម្រេចនោះទេ អគ្គព្រះរាជអាជ្ញាអាចធ្វើការប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចនោះបាន។

ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។

ក្រឡាបញ្ជីចុះលិខិតប្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេស ដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា[85]។

## ២.ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ចូលមក ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍។

ក្រឡាបញ្ជីត្រូវផ្ញើនៅក្នុងរយៈពេលដ៏ខ្លីបំផុតជូនទៅដល់ការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវៈ

- សំណុំរឿងនីតិវិធី
- សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម
- សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។

ក្នុងករណី មានបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការស្តីអំពីការឃុំខ្លួនជនជាប់ចោទ សំណុំរឿងត្រូវបញ្ជូនក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន[86]។

[84] មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
[85] មាត្រា ៣៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
[86] មាត្រា ៣៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវកន្លងមក នូវប្រធានបទ **បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ ចំពោះសាលក្រមព្រហ្មទណ្ឌ** ធ្វើអោយយើងខ្ញុំទទួលបាននូវចំណេះដឹងបន្ថែមជាច្រើន ពីព្រោះថាមុននឹងឈានដល់ដំណាក់កាលជម្រះនឹងចេញសាលក្រម ត្រូវឆ្លងដំណាក់កាលជាច្រើនដូចជា ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌(ធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ប្រមូលភស្តុតាង និងរៀបចំសំណុំរឿងបញ្ជូនមកព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់) ដំណាក់កាលអយ្យការ (ធ្វើការចោទប្រកាន់តាមដីកាសន្និដ្ឋាបញ្ជូនរឿងឱ្យស៊ើបសួរ ប្តឹងអោយចៅក្រមស៊ើបសួរធ្វើការបើកការស៊ើបសួរ) ដំណាក់កាលស៊ើបសួរ (ធ្វើការសាកសួរភាគីដែលពាក់ព័ន្ធ ស៊ើបសួរទាំងដោះបន្ទុក និងដាក់បន្ទុក) ចៅក្រមជំនុំជម្រះ (ធ្វើការពិភាក្សាដេញដោលនាពេលសវនាការដើម្បីធ្វើការសម្រេចសេចក្តី)។ បន្ទាប់ពីបានសម្រេចសេចក្តី និងប្រកាសសាលក្រមរួច តុលាការត្រូវធ្វើការជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ ប្រសិនបើភាគីដែលពាក់ព័ន្ធទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចហើយមិនសុខចិត្តនឹងសេចក្តីនោះអាចធ្វើការប្តឹងឧបាស្រ័យនឹងសេចក្តីសម្រេចនោះបាន។

ឆ្លងតាមការបកស្រាយខាងលើ ដើម្បីជួយសម្រួលដល់ភាគីដែលពាក់ព័ន្ធក្នុងការធ្វើបណ្តឹងឧបាស្រ័យនឹងសេចក្តីសម្រេចរបស់តុលាការ នៅក្នុងបញ្ញត្តនៃមាត្រា ៣៦៦ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីទម្រង់នៃបណ្តឹង និងទីកន្លែងដែលត្រូវធ្វើបណ្តឹង។ ម៉្យាងវិញទៀត បណ្តឹងនោះទៀតសោតត្រូវតែបានធ្វើក្នុងរយៈពេលដែលច្បាប់បានកំណត់ បើមិនដូច្នេះទេបណ្តឹងនោះមិនអាចទទួលយកបានឡើយ ហើយសេចក្តីសម្រេចនោះនឹងចូលជាស្ថាពរ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា បើទោះជាតុលាការបានធ្វើការសម្រេចសេចក្តី និងប្រកាសសាលក្រមហើយក៏ដោយ ប្រសិនបើភាគីពាក់ព័ន្ធមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ ដោយគិតថាតុលាការធ្វើការសម្រេចសេចក្តីមានលក្ខណៈធ្ងន់ពេក ឬស្រាលពេក ឬសំណងមិនមានលក្ខណៈធួនល្មមនឹងព្យសនកម្មដែលកើតមានឡើងនោះទេ អាចធ្វើការប្តឹងឧបាស្រ័យនឹងសេចក្តីសម្រេចនោះបាន។ ការដែលនីតិករបញ្ញត្តបែបនេះធ្វើអោយភាគីពាក់ព័ន្ធមិនបានបាត់បង់នូវសិទ្ធិ និងផលប្រយោជន៍ដែលខ្លួនមាន។

# អនុសាសន៍

ដើម្បីជាអនុសាសន៍ក្នុងការស្រាវជ្រាវកន្លងមកនេះ ក៏ដូចជាឆន្ទានុសិទ្ធិរបស់ចៅក្រមជំនុំជម្រះ ក្នុងការសម្រេចសេចក្តីដោយយុត្តិធម៌ តម្លាភាព សមភាព និងធានាឱ្យមានជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ ចៅក្រមជំនុំជម្រះ នាដំណាក់កាលជំនុំជម្រះ ដំណើរការអនុវត្តនៃនីតិវិធីនៃការជំនុំជម្រះក្តីត្រូវធ្វើតាមលំហូរនៃនីតិវិធីច្បាប់ដែលបានកំណត់ដូចជា ធ្វើការកោះហៅភាគីដែលពាក់ព័ន្ធឱ្យចូលរួមសវនាការដោយគោរពនូវរយៈពេលដែលមានចែងនៅក្នុងបញ្ញត្តិច្បាប់ដែលមានជាធរមាន, ធ្វើការពិភាក្សាដេញដោលក្នុងសាលសវនាការ, ធ្វើការជូនដំណឹងអំពីសេចក្តីសម្រេចជាដើម។

ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំជឿជាក់យ៉ាងមោះមុតថា បើយើងទាំងអស់គ្នាចូលរួមអនុវត្តច្បាប់យ៉ាងខ្ជាប់ខ្ជួន សាមគ្គីគ្នាបម្រើវិស័យយុត្តិធម៌ នោះភាពអយុត្តិធម៌នឹងកើតមានឡើងជាសត្យានុម័ត។ យ៉ាងណាមិញ ប្រធានបទសារណារ **បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌ** របស់យើងខ្ញុំផ្ទាល់ មានទំនាក់ទំនងផលប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធ ដែលធ្វើអោយភាគីទាំងនោះមិនបានបាត់បង់នូវផលប្រយោជន៍ដែលខ្លួនមាន។ ម៉្យាងវិញទៀត ក៏បានចូលរួមជាសំខាន់ក្នុងការបម្រើនូវវិស័យយុត្តិធម៌ ដោយហេតុថា សាលក្រម ឬសាលដីកា នៅពេលដែលចូលជាស្ថាពរ គឺជាលិខិតដែលត្រូវយកទៅអនុវត្តនាពេលអនាគត។

# ឯកសារយោង

## ១/.លិខិតបទដ្ឋានគតិយុត្តិ

១-រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣។

២-ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៣-ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ២/.ឯកសារជាសៀវភៅ និងអត្ថបទ

១-លោកសាស្ត្រាចារ្យ **រុន ពណ្ណរិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** មេរៀននីតិវិធីព្រហ្មទណ្ឌ។

២-គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ លោក **ប៉ុន សារ៉ាត** មេរៀនស្តីពី **បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍។**

៣-គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ លោក **សេង នាង** មេរៀនស្តីពី **បច្ចេកទេសតាក់តែងសាលក្រមព្រហ្មទណ្ឌ។**

- https://www.scribd.com/document
- https://ciclg.com/kh/article/64

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តកណ្តាល
បណ្តឹងទាស់ លេខ 066
ថ្ងៃទី 22 ខែ 12 ឆ្នាំ 20
ម៉ោង 3:30

## <u>ពាក្យបណ្តឹងទាស់</u>

នាងខ្ញុំមេធាវី                    អត្តលេខ១៩៤៥T ដែលមានការិយាល័យ ស្ថិតនៅដីឡូតិ៍លេខ២២ ផ្លូវលេខ៧៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ                    លេខទូរសព្ទ ០១៥ ៣០ ៧០ ៨០ ។

**<u>សូមគោរពជូន</u>**

**<u>ឯកឧត្តមប្រធាន សាលាដំបូងខេត្តកណ្តាល</u>**

ជូន
លោកចៅក្រម និងក្រឡាបញ្ជី
ទទួលបន្ទុក ពិនិត្យជាសមត្ថកិច្ច។

**<u>កម្មវត្ថុ</u>៖** ប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៥ "ណ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល នៅចំណុច "គ" អំពីទោស ត្រង់១.១ នៃសេចក្តីសម្រេច។

**<u>យោង</u>៖** - មាត្រា ៣៦៥ មាត្រា ៣៦៦ និងមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

- សំណុំរឿងព្រហ្មទណ្ឌលេខ៨៧១ អ.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ ឈ្មោះ                    បានពឹងពាក់នាងខ្ញុំជាមេធាវី ដើម្បីការពារសិទ្ធិរបស់គាត់ និងធ្វើបណ្តឹងទាស់នឹងសាលាក្រមកំបាំងមុខលេខ ៣៤៥ "ណ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល ចំណុច "គ" អំពីទោស ត្រង់១.១ នៃសេចក្តីសម្រេច ដែលបានសម្រេច និងប្រកាសជាសាធារណៈកំបាំងមុខកូនក្តីរបស់នាងខ្ញុំឈ្មោះ                    ។ មូលហេតុនៃការប្តឹងទាស់នឹងសាលក្រមកំបាំមុខខាងលើ គឺកូនក្តីរបស់នាងខ្ញុំឈ្មោះ                    មិនសុខចិត្តនឹងទោសដែលតុលាការបានប្រកាស ដោយហេតុថា ទោសនេះ មានលក្ខណៈធ្ងន់ធ្ងរ ពោលគឺមិនសមស្របទៅនឹងទង្វើដែលកូនក្តីរបស់នាងខ្ញុំបានប្រព្រឹត្ត។

អាស្រ័យដូចបានជម្រាបខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងទទួលពាក្យបណ្តឹងទាស់ខាងលើនេះ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលការគោរព ដ៏ជ្រាលជ្រៅអំពីនាងខ្ញុំ៕

ថ្ងៃច័ន្ទ ៧កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

**ហត្ថលេខា និងត្រា**

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

<u>ឯកសារភ្ជាប់</u>៖
១-ពាក្យការពារក្តី និងពាក្យពឹងពាក់មេធាវីរបស់ឈ្មោះ សាន ច័ន្ទថា ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០។
២-សាលក្រមព្រហ្មទណ្ឌលេខ ៣៤៥ "ណ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តកណ្តាល**

## ដីកាបង្គាប់ឲ្យឃុំខ្លួន

លេខ......០១៦......យ.អក

យើង　　　　　តំណាងអយ្យការអមសាលាដំបូង ខេត្តកណ្តាល។

- បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស.រក.ម/០៨០៧ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។
- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៨ អក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។
- បានឃើញ ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៩៩៩ ដកសចខ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២០ របស់ចៅជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល។
- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ២៥៦ (ថ) ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទ៖

ឈ្មោះ　　　　　ភេទប្រុស អាយុ ៣០ ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ មិនពិតប្រាកដ ទីលំនៅបច្ចុប្បន្នភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ប្រពន្ធឈ្មោះ　　　　　មានកូន ០១នាក់ ឪពុកឈ្មោះ　　(រស់) ម្តាយឈ្មោះ　　(រស់) ។

តុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល **១៨ (ដប់ប្រាំបី) ខែ** ពីបទ លួច ប្រព្រឹត្តនៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា **៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ** តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ **២៥៦** (ថ) ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល។

### សម្រេច

បង្គាប់ឲ្យប្រធានពន្ធនាគារខេត្តកណ្តាលទទួលឃុំខ្លួនឈ្មោះ　　　　　ភេទប្រុស អាយុ ៣០ ឆ្នាំ ជាបណ្តោះអាសន្ន រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

ថ្ងៃពុធ ១២[illegible]នូ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅកណ្តាល ថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០២១
តំណាងអយ្យការ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំពឹងពាក់មេធាវី

នាងខ្ញុំ/ខ្ញុំបាទឈ្មោះ ......... [illegible].. ភេទ [illegible]...ជាតិខ្មែរ សញ្ជាតិខ្មែរ ជា.[illegible]......... ទីលំនៅបច្ចុប្បន្ន.......................... ផ្លូវ............ ភូមិ.[illegible]........ ឃុំ/សង្កាត់..[illegible]..... ស្រុក/ខណ្ឌ..[illegible]...... ខេត្ត/រាជធានី..[illegible]........។

**សូមពឹងពាក់**

កញ្ញាមេធាវី អត្តលេខ១៩៤៥T មានការិយាល័យឈ្មោះ ស្ថិតនៅដីឡូត៍លេខ២២ ផ្លូវលេខ៧៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ដើម្បីការពារសិទ្ធិឲ្យខ្ញុំបាទ និងនាងខ្ញុំ ព្រមទាំងធ្វើបណ្តឹងជំនួសនាងខ្ញុំ និងខ្ញុំបាទ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ [illegible]... ចុះថ្ងៃទី...19... ខែ.[illegible] ឆ្នាំ២០២០ របស់ តាមនីតិវិធីច្បាប់ចាប់ពីថ្ងៃផ្តិតមេដៃ ឬចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..13.. ខែ.[illegible]...... ឆ្នាំ២០២០

**ស្នាមមេដៃស្តាំអ្នកពឹងពាក់**

**បានឃើញ និងយល់ព្រម**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី13.. ខែ.[illegible]...... ឆ្នាំ២០២០

**ហត្ថលេខា និងត្រា**

ATTORNEY AT LAW

KINGDOM OF CAMBODIA

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យការពារក្តី

នាងខ្ញុំមេធាវី អត្តលេខ១៩៣៨T មានការិយាល័យឈ្មោះ ស្ថិតនៅក្រុម១១ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងនាងខ្ញុំមេធាវី អត្តលេខ១៩៤៥T ដែលមានការិយាល័យ ស្ថិតនៅដីឡូតិ៍លេខ២២ ផ្លូវលេខ៧៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ លេខទូរសព្ទ ០១៥ ៣០ ៧០ ៨០ ។

## សូមគោរពជូន

## ឯកឧត្តមប្រធាន សាលាដំបូងខេត្តកណ្តាល

**កម្មវត្ថុ:** ការចូលការពារក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៨៧១ អ.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល

**យោង:** - ពាក្យសុំពឹងពាក់មេធាវីរបស់ឈ្មោះ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០

- មាត្រា២ និងមាត្រា៣នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- មាត្រា៩៨ និងមាត្រា២៩៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: យើងខ្ញុំត្រូវបានឈ្មោះ សុំពឹងពាក់ឱ្យការពារក្តីក្នុងសំណុំរឿងខាងលើ តាមនីតិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបតាមការគួរ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃសុក្រ ៤ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០

ហត្ថលេខា និងត្រា

**ផ្ញើភ្ជាប់ជាមួយ:**

ពាក្យសុំពឹងពាក់មេធាវី ចំនួន០២ច្បាប់

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៨ អក
ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២០

# កំណត់ហេតុជូនដំណឹងពីសាលក្រមកំបាំងមុខ

ឆ្នាំពីរពាន់ម្ភៃមួយ ខែ**មីនា** ថ្ងៃទី **ដប់** វេលាម៉ោង ដប់មួយ និង ដប់ប្រាំនាទី ព្រឹក ។

យើង តំណាងអយ្យការអមសាលាដំបូង ខេត្តកណ្តាល មានលោក ជាក្រឡាបញ្ជី អមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ ៣០ ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ មិនពិតប្រាកដ ទីលំនៅបច្ចុប្បន្ននៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ប្រពន្ធឈ្មោះ មានកូន ០១នាក់ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់)។

ខ្ញុំពុំដែលបានទទួលដំណឹងអំពី សាលក្រមខាងលើនោះទេ ដោយខ្លួនបានដឹងពេលដែលគេចាប់ខ្លួន នេះតែប៉ុណ្ណោះ។

យើងបានអានសាលក្រមព្រហ្មទណ្ឌលេខ ២៥៦ (ថ) ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០ របស់សាលា ដំបូងខេត្តកណ្តាល ឲ្យឈ្មោះ បានស្តាប់ថា ខ្លួនត្រូវបានតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារ កំណត់រយៈពេល **១៨ (ដប់ប្រាំបី)** ខែ ពីបទ៖ **លួច** ប្រព្រឹត្តនៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្ត កណ្តាល កាលពីថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០២០ តាមបញ្ញត្តិមាត្រា **៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ** តាម អំណាចសាលក្រមព្រហ្មលេខ ២៥៦ (ថ) ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០ របស់សាលា ដំបូងខេត្តកណ្តាល។

ឈ្មោះ ភេទប្រុស អាយុ ៣០ ឆ្នាំ កន្លងមកខ្លួនមិនបានទទួលដំណឹងពីសាលក្រមព្រហ្ម លេខ ២៥៦ (ថ) ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០ របស់សាលា ដំបូងខេត្តកណ្តាល នោះទេ គឺខ្លួនទើបតែបាន ដឹងនៅពេលដែលសមត្ថកិច្ចធ្វើការឃាត់ខ្លួន ហើយខ្លួនក៏មិនសុខចិត្តទទួលយកសេចក្តី សម្រេចដែលមានក្នុង សាលក្រមព្រហ្មទណ្ឌខាងលើទេ ហើយខ្លួនសុំប្តឹងទាស់នឹងសាលក្រមខាងលើ ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ដប់មួយ និង សាមសិបនាទី នាថ្ងៃខែឆ្នាំដដែល ហើយបានអានឲ្យ សាមីខ្លួនស្តាប់ ឆ្លើយថា ត្រឹមត្រូវហើយនឹងយល់ព្រមផ្តិតមេដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

-សាលក្រមនេះជំនុំជំរះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ចំពោះមុខដើមបណ្តឹងឈ្មោះ និងកំបាំងមុខជនជាប់ចោទឈ្មោះ ។

ទុកសិទ្ធឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃ.ព្រហស្បតិ៍ ១៥កើត...ខែ.បុស្ស........ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កណ្តាល, ថ្ងៃទី.....២៨........ខែ.....១.......... ឆ្នាំ២០២១

**តំណាងអយ្យការ**

*យើង...........................................................................ជា..............................................*

*ប្រគល់លិខិតជូនដំណឹងនេះដល់ឈ្មោះ:..........................................................................................*

*.ទីលំនៅសព្វថ្ងៃនៅភូមិ....................ឃុំ/សង្កាត់.............................................ស្រុក/ខណ្ឌ...............*

*..................ខេត្ត/ក្រុង....................នៅថ្ងៃទី......................ឆ្នាំ២០២០ រួចហើយបានប្រាប់ថា បើមិនសុខចិត្ត នឹងសេចក្តីសម្រេចរបស់តុលាការនេះទេ ត្រូវអញ្ជើញទៅប្តឹងឧទ្ធរណ៍ នៅការិយាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល ក្នុងកំណត់ច្បាប់គិតពីថ្ងៃទទួល ដំណឹងនេះតទៅ។*

**អ្នកទទួល**

ហត្ថលេខា ឬស្នាមមេដៃស្តាំ

**អ្នកប្រគល់**

ហត្ថលេខា ឬស្នាមមេដៃស្តាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៤៨ អ.ក
ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០២០
សាលក្រមលេខ: ២៥៦"ឫ"
ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២០

## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៨:៣០ ព្រឹក ដោយមានសមាសភាពដូចតទៅ:

ចៅក្រមជំនុំជម្រះ

លោក ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកណ្តាល

តំណាងអយ្យការ

លោក ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងខេត្តកណ្តាល

ក្រឡាបញ្ជីសវនាការ

លោកស្រី ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៨ អក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ

ភេទប្រុស អាយុ៣០ ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិធម្មត្រ័យ សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់) ប្រពន្ធឈ្មោះ មានកូន ០១នាក់ ជានីតិជន (ក្រៅឃុំ) ។

-ត្រូវជាប់ចោទពីបទ៖ លួច ប្រព្រឹត្តនៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៧១ ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ។

## ដំណាលរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង៩និង៤០នាទីជនរងគ្រោះឈ្មោះ បានជិះម៉ូតូមួយគ្រឿងម៉ាក HONDA DREAM C125ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1FH-7115 មកទុកនៅបរិវេណវត្តទួលស្លែង ស្ថិតនៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ដោយពុំបានដកកូនសោចេញពីម៉ូតូទេ។ភ្លាមនោះក៏មានជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពលបលួចម៉ូតូខាងលើយកទៅបាត់តែម្តង។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១.តាមចម្លើយរបស់សាក្សី តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និង តាមការពិនិត្យឯកសារនានានៅក្នុងសំណុំរឿងឃើញថា គឺពិតជាមានអង្គហេតុដូចការចោទប្រកាន់របស់តំណាងអយ្យការដែលបានចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ ដែលបានធ្វើសកម្មភាពលួចម៉ូតូ ០១ គ្រឿង ម៉ាក ហុងដាឌ្រីម សេ១២៥ ពាក់ស្លាកលេខ ភ្នំពេញ 1FH-7115 កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង០៩និង៤០នាទី ដែលជនរងគ្រោះឈ្មោះ បានទុកម៉ូតូរបស់ខ្លួនស្ថិតនៅចំណុចបរិវេណវត្តទួលស្លែង ស្ថិតនៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល ពិតប្រាកដមែន។

២-ជនជាប់ចោទឈ្មោះ ជានីតិជន ហើយជនជាប់ចោទមានស្មារតី និង សមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ចំពោះមុខច្បាប់ពោល គឺជនជាប់ចោទ មិនមានសញ្ញាណណាមួយដែលបង្ហាញថា ជនជាប់ចោទមានសតិវិបល្លាស ស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយដែលជាហេតុនាំមិនអោយមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនឡើយ។

៣-តាមអំណានចម្លើយរបស់ជនជាប់រងគ្រោះឈ្មោះ ដែលបានឆ្លើយថា នៅមុនពេលកើតហេតុថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០វេលាម៉ោងប្រហែល៩និង៤០នាទី ខ្លួនបានជិះម៉ូតូ ម៉ាក HONDA 125 សេរីឆ្នាំ២០១៥ ពណ៌ខ្មៅពាក់ស្លាកលេខ 1FH7115 ភ្នំពេញ ចេញពីផ្ទះមកវត្តទួលស្លែងបានឈប់ទុកនៅមុខកាំជណ្ដើរសាលាធម្មសុធារួចក៏បានឡើងទៅហូបបាយ ដោយយកកូនសោទៅជាមួយ ពេលហូបបាយរួចក៏ចុះមកវិញជិះម៉ូតូទៅកំពុងវត្តមើលទុកចំបូងរបស់វត្តរួចក៏បានជិះម៉ូតូនេះមកវិញ នៅខាងម៉ាស៊ិនភ្លើងរកចបកាប់រួចក៏បានជិះម៉ូតូនេះចេញមកឈប់នៅមុខសាលាធម្មសុធា ដោយពុំបានដកសោរចេញពីម៉ូតូចេញទេ ហើយបានដើរឡើងទៅលើសាលា ដើម្បីរកកូនសោរនិងម៉ាឡេតយកទៅដោះខ្សែកាប នៅឯកំពង់ចម្លង់បានមួយសន្ទុះ ខ្លួនក៏បានចុះមកវិញស្រាប់តែមិនឃើញម៉ូតូ ខ្លួនក៏បានដើររកមើលក្បែរៗសាលាតែមិនឃើញសោះក៏បានឲ្យឈ្មោះអាត តេទូរស័ព្ទប្ដឹងទៅសមត្ថកិច្ចភ្លាមៗដែរក្នុងករណីបាត់ម៉ូតូរបស់ខ្លួននេះ បន្ទាប់មកខ្លួននិងបងប្អូនរួមទាំងសមត្ថកិច្ចក៏បានពួនស្ទាក់ស្វែងរកគ្រប់ផ្លូវនៅគ្រប់ទីកន្លែងតែមិនបានជួបប្រទះឡើយ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ នៅព្រឹកថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែលប្រាំបី ខ្លួនបានជិះម៉ូតូយកទៅធ្វើនៅផ្សារកោះធំ តែជាងបានបិទទ្វារ ខ្លួនក៏បានជិះត្រឡប់មកវិញដោយល្បឿនយឺតៗ ។ពេលមកដល់ផ្ទះឈ្មោះ ខ្លួនបានឃើញឈ្មោះ ភេទប្រុស ជិះម៉ូតូពណ៌ខ្មៅសេរី២០១៥ពាក់អាវយឺតស្លៀកខោខ្លី ជិះម្នាក់ឯងគ្មានពាក់មួកយ៉ាងលឿន ពីកើតទៅលិច លុះពេលខ្លួនមកដល់ផ្ទះប្រហែលកន្លះម៉ោងទើបមានព័ត៌មានថា មានបាត់ម៉ូតូរបស់ឈ្មោះ នៅវត្តទួលស្លែង អញ្ចឹងបានខ្លួនបានឃើញឈ្មោះ បានជិះម៉ូតូយ៉ាងលឿនប្រួសជាមួយខ្លួន ។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ខ្លួនបានកំពុងលក់ភេសជ្ជៈនៅក្នុងវត្តទួលស្លែង នៅពេលព្រឹកខណៈនោះខ្លួនបានឃើញបុរសម្នាក់មិនស្គាល់ឈ្មោះ តែដឹងថាត្រូវជាប្ដីរបស់ឈ្មោះ បានដើរតាមផ្លូវកាត់តាមមុខរោងខ្លួនកំពុងលក់។ បានមួយសន្ទុះក្រោយមកខ្លួនក៏បានឃើញបុរសរូបនេះបានដើរកាត់តាមមុខរោងចូលទៅក្នុងវត្តបាត់ទៅ។ បន្ទាប់មកបានមួយសន្ទុះស្រាប់តែមានការភ្ញាក់ផ្អើលឡើងថាមានគេលួចម៉ូតូរបស់កុងស្រ៊ាងបាត់ហើយ។

- តាមចម្លើយអំណានម្លើយរបស់សាក្សីឈ្មោះ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ៩ទៅដល់ម៉ោង១០ ខ្លួនបានឃើញឈ្មោះ មិនស្គាល់ត្រកូលភេទប្រុសបានមកទិញប៊ីយ៉េរនៅផ្ទះខ្លួនមួយសន្ទុះក៏បានចេញពីផ្ទះខ្លួនបាត់ទៅ។ ក្រោយបន្តិចស្រាប់តែមានបងប្អូនជិតខាងបានមកទិញអីវ៉ាន់របស់ខ្លួននិយាយប្រាប់ថាគណៈកម្មការភូមិទួលស្លែងបាត់ម៉ូតូ នៅចន្លោះម៉ោង៩ទៅ១០ពេលនោះក៏មានបងប្អូនភ្ញាក់ផ្អើលឡើងតែម្តង។

យោងតាមចម្លើយរបស់ជនរងគ្រោះ អំណានចម្លើយរបស់សាក្សី និងរបាយការណ៍របស់នគរបាលយុត្តិធម៌ គឺអាចឱ្យតុលាការជឿបានថាជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើលួច ពិតប្រាកដមែន។

៤.យោងតាមចំណុចទី៣ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះឃើញថា បច្ច័យទាំងនេះគឺកើតចេញ ពីអំពើរបស់ជនជាប់ចោទដោយផ្ទាល់ ដែលតំរូវជនជាប់ចោទទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។

៥.ធាតុអត្តោម័តរបស់ជនជាប់ចោទ តាមអំណានចំលើយរបស់ជនរងគ្រោះ អំណានចម្លើយរបស់សាក្សី និងរបាយការណ៍របស់នគបាលយុត្តិធម៌សង្វាក់គ្នា នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី គឺជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើលួចប្រាកដមែន ជនជាប់ចោទមានការយល់ដឹងយ៉ាងច្បាស់ថាវត្ថុដែលខ្លួនយកនោះមិនមែនជាកម្មសិទ្ធរបស់ខ្លួន តែខ្លួននៅតែមានឆន្ទៈក្នុងការលួចដោយបានធ្វើសកម្មភាពលួច។ សកម្មភាពទាំងនេះគឺអាចបញ្ជាក់ពីកំរិតនៃការយល់ដឹង និង ធាតុ អត្តោម័ត របស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៦.អំពើរបស់ជនជាប់ចោទឈ្មោះ ជាអំពើមួយដែលធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ប៉ះពាល់ដល់សន្តិសុខសង្គម ពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជនរបស់អ្នកដ៏ទៃ គប្បីតុលាការសំរេចធ្វើការប្រកាសទោសអោយជនជាប់ចោទទទួលខុសត្រូវតាមបញ្ញាត្តិមាត្រាខាងលើ។

៧.ដោយផ្អែកតាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ អំណានចម្លើយរបស់សាក្សីនិងរបាយការណ៍របស់នគបាលយុត្តិធម៌អាចអោយជឿបានថាៈ ជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តបទល្មើស៖ លួច ពិតប្រាកដមែន ហេតុដូចនេះ តំណាងអយ្យការនៅតែសម្រេចតម្កល់ការចោទប្រកាន់ទៅដីកាសន្និដ្ឋានស្ថាពរលេខៈ ២១៩ ជក.សព ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

៨- មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសទៅលើ៖ ជនជាប់ចោទឈ្មោះ

ជាអំពើមួយដែលច្បាប់បញ្ញត្តិចែងថាជាអំពើៈ លួច ប្រព្រឹត្តនៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ដែលត្រូវផ្តន្ទាទោសតាម មាត្រា**៣៥៣ និងមាត្រា ៣៥៦ នៃ** ក្រមព្រហ្មទណ្ឌ។

៩- ដោយជនជាប់ចោទឈ្មោះ ក្រោយពីបានប្រពឹត្តបទល្មើសរួចជនជាប់ចោទខាងលើបានធ្វើការរត់គេចខ្លួន គប្បីតុលាការសម្រេចធ្វើការផ្តន្ទាទោសជនជាប់ចោទខាងលើចំនួន ១៨ខែ ដោយផ្អែកលើមាត្រា៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការសម្រេចធ្វើការចេញដីកាចាប់ខ្លួនជនជាប់ចោទ ខាងលើដើម្បីយកមកធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**ហេតុដូចនេះសាលាដំបូងកណ្តាល**

**វិនិច្ឆ័យសេចក្តី**

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ដែលមានសាវតាជាតិដូចខាងលើដាក់ពន្ធនាគារ ចំនួន ១៨ (ដប់ប្រាំបី) ខែ ពីបទ៖ **លួច ប្រព្រឹត្តនៅភូមិទួលស្លែង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល** កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ **តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។**

២.ចេញដីកាចាប់ខ្លួនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៣០ ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិធម្មត្រ័យ សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅភូមិទួលស្លែងឃុំលើកដែកស្រុកកោះធំ ខេត្តកណ្តាលឪពុកឈ្មោះ (រស់)ម្តាយឈ្មោះ (រស់) ប្រពន្ធឈ្មោះ មានកូន ០១នាក់ ជានីតិជន ។(ក្រៅឃុំ)

សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ចំពោះមុខដើមបណ្តឹង និងកំបាំងមុខជនជាប់ចោទ។

ទុកសិទ្ធអោយប្តឹងទាស់ និង ឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| សាលាដំបូង ខេត្តកណ្តាល | |
|---|---|
| បណ្តឹងឧទ្ធរណ៍ | លេខ 096<br>ថ្ងៃទី 6 ខែ 7 ឆ្នាំ 20<br>ម៉ោង 10:00 |

ថ្ងៃ ចន្ទ ០១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦
រាជធានី ភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០

**<u>ពាក្យបណ្តឹងឧទ្ធរណ៍</u>**

មេធាវី អត្តលេខ និងមេធាវី អត្តលេខ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យមេធាវី

**ផ្ទើង** ទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីឈ្មោះ (ពិរុទ្ធជន)ដើម្បីប្តឹងឧទ្ធរណ៍ជំនួសគាត់។

លោកចៅក្រម និងក្រឡាបញ្ជី **សូមគោរពជូន**

ទទួលបន្ទុក ពិនិត្យជាសមត្ថកិច្ច **ឯកឧត្តម ប្រធានសាលាដំបូងខេត្ត កណ្តាល**

**<u>កម្មវត្ថុ</u>** : សុំប្តឹងឧទ្ធរណ៍ចំពោះ**សាលក្រមព្រហ្មទណ្ឌលេខ** ចុះ**ថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ ២០២០** របស់សាលាដំបូងខេត្ត កណ្តាល **គ្រប់ចំណុចទាំងមូលនៃសាលក្រមនេះ។**

**<u>យោង</u>** : សំណុំរឿងព្រហ្មទណ្ឌលេខ អក ចុះថ្ងៃទី**២៥** ខែកក្កដា ឆ្នាំ២០១៨ និង **សាលក្រមព្រហ្មទណ្ឌលេខ** ចុះថ្ងៃទី**០៩** ខែ **មិថុនា ឆ្នាំ២០២០** របស់សាលាដំបូងខេត្ត **កណ្តាល** ។

- លិខិតប្រគល់សិទ្ធិ របស់ឈ្មោះ ចុះថ្ងៃទី០២. ខែ**កក្កដា ឆ្នាំ២០២០**។

តតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជំរាបជូន **លោក ប្រធានសាលាដំបូង** មេត្តាជ្រាបថា **សាលក្រមព្រហ្មទណ្ឌលេខ** ចុះថ្ងៃទី**០៩** ខែ **មិថុនា** ឆ្នាំ២០២០ របស់សាលាដំបូងខេត្ត **កណ្តាល** មិនបានផ្តល់យុត្តិធម៌ដល់កូនក្តីយើងខ្ញុំឈ្មោះ ទេ ដោយមូលហេតុថា ការសម្រេចផ្តន្ទាទោសដល់ឈ្មោះ មិនសមស្របនឹងកត្តាសត្យានុម័ត និងអត្តនោម័ត **ដោយហេតុថាទី១ កូនក្តីបានសារភាពថា ប្រើហិង្សាដោយការពារខ្លួន ទី២ ពុំមានការប្រើអាវុធ ទី៣ ព្យសនកម្មតិចតួច(ជនរងគ្រោះ មិនមានរបួសធ្ងន់ធ្ងរ) ដែលគួរតែសម្រេចក្នុងការផ្តល់ស្ថានភាពសម្រាលទោសដល់គាត់។**

សេចក្តីដូចបានជំរាបជូនខាងលើនេះ សូម **លោក ប្រធានសាលាដំបូង** មេត្តាចាត់ការបញ្ជូនសំណុំរឿងព្រហ្មទណ្ឌ**ដូចយោងខាងលើ** ទៅសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមនីតិវិធីច្បាប់កំណត់។

**សូម លោក ប្រធានសាលាដំបូង** មេត្តាទទួលនូវការគោរពអំពីយើងខ្ញុំ ។

<u>សូមជូនភ្ជាប់មកជាមួយនូវ:</u>
លិខិតប្រគល់សិទ្ធិប្តឹងឧទ្ធរណ៍

ព្រះរាជាណាចក្រកម្ពុជា
មេធាវី

អាសយដ្ឋាន៖ អាគារក្រុមហ៊ុន អាគារលេខ២០៣ ជាន់ទី២ មហាវិថី ម៉ៅសេទុង
សង្កាត់ ទួលស្វាយព្រៃ២ ខណ្ឌ ចំការមន រាជធានី ភ្នំពេញ
លេខទូរស័ព្ទ៖ ០៨៨ ៧៦៩ ៧៨៦៨ / ០៧៦ ៧៦៩ ៧៨៦៨ និង ០១៧ ៧១០០៧១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

-សំណុំរឿងព្រហ្មទណ្ឌលេខៈ

ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨

-សាលក្រមលេខ៖

ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកណ្ដាល**

-បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ដោយមាន សមាសភាពដូចតទៅៈ

**ចៅក្រមជំនុំជំរះ**

លោកស្រី ចៅក្រម សាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោកស្រី ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះបណ្ដឹងទាស់លើសាលក្រមលេខៈ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ សំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ ដែលមានពិរុទ្ធជនដូចខាងក្រោម ៖

-ឈ្មោះ ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិក្បាលកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) នៅលីវ ។ (ឃុំខ្លួនថ្ងៃទី )

ជាប់ចោទពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិក្បាលគោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិព្រែកតាហ៊ីង ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ននៅភូមិក្បាលកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (ស) ប្រពន្ធឈ្មោះ មានកូន ០៥នាក់ ។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ១២ ថ្ងៃត្រង់ ឈ្មោះ បានដេញចាប់មាន់ កែចាប់ច្រលំមាន់របស់ឈ្មោះ ភេទប្រុស ហើយឈ្មោះ ក៏បានប្រលែងមាន់វិញ ហើយមាន់នោះ

បានរត់ចូលទៅក្នុងគុម្ពឬស្សី ស្របពេលនោះមានសត្វឆ្មា បានដេញខាំមាន់នោះ ហើយឈ្មោះ ឃើញសត្វឆ្មាដេញខាំមាន់ក៏បានទាញដែកបំរុងទៅចាក់សត្វឆ្មា ពេលកំពុងរកសត្វឆ្មានោះ ស្រាប់តែឈ្មោះ បានស្ទុះទៅវាយឈ្មោះ និងបោកផ្ទប់ទៅនឹងដីបណ្ដាលឱ្យហើម និងជាំថ្គាមខាងស្ដាំ ពេលនោះក៏មានអ្នកជិតខាងចូលមកឃាត់បំបែកគ្នាចេញទៅ ។

បានឃើញ សាលក្រមលេខៈ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាលដែលមានខ្លឹមសារ ៖

១-ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៨ឆ្នាំ ដាក់ពន្ធនាគាកំណត់រយៈពេល ០៣ (បី) ឆ្នាំ ។

ពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិក្បាលកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យចាប់ខ្លួន ឃុំខ្លួនលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៨ឆ្នាំ ដាក់ ពន្ធនាគារ ខេត្តកណ្ដាល គិតចាប់ពីថ្ងៃចាប់ខ្លួនបាន ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ សងសំណងជម្ងឺចិត្តទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ ចំនួន **១០,០០០,០០០ រ (ដប់លានរៀល)** ការទាមទារលើសពីនេះបដិសេធចោល ។

-សាលក្រមនេះជំនុំជំរះជាសារធារណៈ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០១៩ កំបាំងមុខជនជាប់ចោទ និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី ទុកសិទ្ធឱ្យប្ដឹងទាស់ ប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ ពាក្យសុំប្ដឹងទាស់លេខៈ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ របស់ឈ្មោះ ហៅ ស្វិត ដែលមានខ្លឹមសារៈ

"សំណើសុំប្ដឹងទាស់ និងសាលក្រមលេខៈ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល និងសេចក្ដីសម្រេច នៃសាលក្រមទាំងមូល ។

## <u>នាពេលសវនាការ</u>

-ពិរុទ្ធជនឈ្មោះ បានឆ្លើយថា ខ្លួនប្ដឹងទាស់នឹងសាលក្រមនេះ ព្រោះខ្លួនមិនសុខចិត្តនឹងសេចក្ដីសម្រេចនោះទេ។ រឿងហេតុនេះ គឺគាត់ជាអ្នកបង្កឡើងមុន គាត់វាយខ្លួនមុន។ ខ្លួនគ្រាន់តែការពារខ្លួនប៉ុណ្ណោះ។ ខ្លួនមិនបានគេចខ្លួនទៅណាទេ ខ្លួនទៅធ្វើការនៅកំពង់សោម។ រឿងហេតុចោទប្រកាន់នោះ គឺគ្មានទេ ពេលនោះគ្មានឆ្មារទេ។ ខ្លួនមានសាក្សីអ្នកផឹកជាមួយគ្នា។ រឿងហេតុ កើតឡើងនៅថ្ងៃណាខ្លួនមិនចាំទេ ខ្លួនដឹងតែថាពេលនោះថ្ងៃត្រង់។ ចម្លើយរបស់ឈ្មោះ ខ្លួនទទួលស្គាល់។ ឈ្មោះ វាយខ្លួនមុន ហើយខ្លួនការពារខ្លួន ក៏ត្រូវកែងពីរកែង ប៉ោងថ្គាមរបស់ឈ្មោះ ។ អង្គហេតុខ្លួនវាយឈ្មោះ ០២កែង ខ្លួនសារភាព ប៉ុន្តែចំពោះការសម្រេចផ្ដន្ទាទោសខ្លួន រយៈពេល ០៣ឆ្នាំនោះ ខ្លួនទទួលយកមិនបាននោះទេ។ ខ្លួនមិនបានគម្រាមសម្លាប់ឈ្មោះ នោះទេ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ពេលនោះ ខ្លួនផឹកស្រាអស់០១ កែវ ប៉ុណ្ណោះ។ ខ្លួនមិនបានវាយវាទេ ខ្លួនគ្រាន់តែគោះខ្នងវា បន្តិចប៉ុណ្ណោះ។ វាវាយខ្លួនដាក់យកៗតែម្ដង។ វាវាយខ្លួនឡើងប៉ោងថ្ងាម ឡើងខ្នុះ និងជាំដើមទ្រូង។ ខ្លួនសម្រាកព្យាបាលរបួសអស់ប្រាក់ប្រហែល ១០០០ ដុល្លារអាមេរិក។ ខ្លួនមិនដែលមានទំនាស់អ្វីនឹងវានោះទេ។ ខ្លួនបានយករបស់អ្វីទៅចាក់គេនោះទេ។ រឿងហេតុ កើតឡើងដោយសារគប់មាន់។ ខ្លួនសំណូមពរសុំឱ្យតុលាការរក្សាសាលក្រមដើម ទុកនៅដដែល។

-អំណានចម្លើយរបស់សាក្សីឈ្មោះ នាពេលសវនការបានឆ្លើយថា កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ១២ ថ្ងៃត្រង់ ខ្លួនកំពុងតែពរចៅនៅក្រោមផ្ទះ ហើយមានគេកំពុងអង្គុយផឹកស៊ីនៅក្រោមផ្ទះរបស់ខ្លួនមានឈ្មោះ , ឈ្មោះ និងកូនរបស់ខ្លួនឈ្មោះ ឈ្មោះ ពេលនោះកូនរបស់ខ្លួនឈ្មោះ បានប្រើឈ្មោះ ទៅគប់មាន់របស់ខ្លួន តែពេលនោះឈ្មោះ គប់ច្រឡំមាន់ គឺទៅគប់មាន់របស់ឈ្មោះ វិញ ឃើញដូច្នេះឈ្មោះ ក៏ស្រែកប្រាប់ឈ្មោះ ថាហែងគប់ច្រឡំមាន់ហើយ គឺមាន់របស់អញទេ ឮដូច្នេះឈ្មោះ ក៏លែងមាន់នោះទៅវិញ បានមួយសន្ទុះខ្លួនឮគេស្រែកឈ្លោះគ្នា នៅមុខផ្ទះរបស់ខ្លួនចម្ងាយប្រហែល ដប់ម៉ែត្រ ខ្លួនក៏ទៅមើលស្រាប់តែឃើញឈ្មោះ កំពុងតែឈរ ចំណែកឯឈ្មោះ ដួលដេកទៅលើដី ហើយ ឃើញស្នាមប៉ោងថ្ពាល់ខាងស្ដាំយ៉ាងខ្លាំង ពេលនោះខ្លួនឃើញឈ្មោះ រកវ៉ៃឈ្មោះ បន្ថែមទៀតតែត្រូវខ្លួនចាប់ឃាត់ទាញដៃឈ្មោះ ឱ្យដើរទៅផ្ទះទៅ ចំណែកឯឈ្មោះ ខ្លួនបានលើកគាត់ឱ្យងើបឈរឡើង ហើយគាត់ដើរទៅផ្ទះខ្លួនឯងទៅ ខ្លួនមិនបានសួររកហេតុផលដែលអ្នកទាំងពីរនោះវ៉ៃគ្នាទេ ។ ចំពោះរឿងហេតុក្រៅពីនេះខ្លួនពុំបានដឹងទេ ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានថាៈ នៅពេលនេះ ដោយសារមានទំនាស់គ្នា ហើយជនជាប់ចោទ បានសារភាពថា ខ្លួនពិតជាបានកែងទៅឈ្មោះ ចំនួន ០២កែង ធ្វើឱ្យឈ្មោះ រងរបួសដូចក្នុងរូបថត ប្រាកដមែន។ ហេតុដូច្នេះ តំណាងអយ្យការ នៅតែរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំឱ្យតម្កល់ សាលក្រមដើម ទុកជាបានការដដែល។

-សំដីចុងក្រោយរបស់ពិរុទ្ធឈ្មោះ សំណូមពរអោយតុលាការមេត្តាបន្ធូរបន្ថយទោសអោយខ្លួនផង ។

ក្រោយពីបានស្ដាប់ចម្លើយរបស់ពិរុទ្ធជន

ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់ចំដីចុងក្រោយរបស់ពិរុទ្ធជន

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**<u>សាលាដំបូងខេត្តកណ្ដាល</u>**

**<u>យល់ឃើញថា</u>**

-តាមពាក្យបណ្តឹងទាស់ លេខ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ របស់ឈ្មោះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ដែលអាចឱ្យតុលាការ លើកយកមកពិនិត្យ និងពិចារណាបាន តាមមាត្រា ៣៦២ និងមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពិតជាមានអំពើ ហិង្សាដោយចេតនា កើតមាននៅភូមិព្រែកតាហ៊ីង ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ដែលបង្កឡើងដោយឈ្មោះ ពិតប្រាកដមែន ។

-តាមចម្លើយជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្លួនប្តឹងទាស់នឹងសាលក្រមនេះ ព្រោះខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនោះទេ។ រឿងហេតុនេះ គឺគាត់ជាអ្នកបង្កឡើងមុន គាត់វាយខ្លួនមុន។ ខ្លួនគ្រាន់តែការពារខ្លួនប៉ុណ្ណោះ។ ខ្លួនមិនបានគេចខ្លួនទៅណាទេ ខ្លួនទៅធ្វើការនៅកំពង់សោម។ រឿងហេតុចោទប្រកាន់នោះ គឺគ្មានទេ ពេលនោះគ្មានឆ្នាទេ។ ខ្លួនមានសាក្សីអ្នកផឹកជាមួយគ្នា។ រឿងហេតុ កើតឡើងនៅថ្ងៃណាខ្លួន មិនចាំទេ ខ្លួនដឹងតែថាពេលនោះថ្ងៃត្រង់។ ចម្លើយរបស់ឈ្មោះ ខ្លួនទទួលស្គាល់។ ឈ្មោះ វាយខ្លួនមុន ហើយខ្លួនការពារខ្លួន ក៏ត្រូវកែងពីរកែង ប៉ោងថ្គាមរបស់ឈ្មោះ ។ អង្គហេតុខ្លួនវាយឈ្មោះ ០២កែង ខ្លួនសារភាព ប៉ុន្តែចំពោះការសម្រេចផ្តន្ទាទោសខ្លួន រយៈពេល ០៣ឆ្នាំនោះ ខ្លួនទទួលយកមិនបាននោះទេ។ ខ្លួនមិនបានគម្រាមសម្លាប់ឈ្មោះ នោះទេ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ពេលនោះ ខ្លួនផឹកស្រាអស់០១កែវ ប៉ុណ្ណោះ។ ខ្លួនមិនបានវាយវាទេ ខ្លួនគ្រាន់តែគោះខ្នងវា បន្តិចប៉ុណ្ណោះ។ វាវាយខ្លួនដាក់យកៗតែម្តង។ វាវាយខ្លួនឡើងប៉ោងថ្គាម ឡើងខ្ទុះ និងជាំដើមទ្រូង។ ខ្លួនសម្រាកព្យាបាលរបួសអស់ប្រាក់ប្រហែល ១០០០ ដុល្លារអាមេរិក។ ខ្លួនមិនដែលមានទំនាស់អ្វីនឹងវានោះទេ។ ខ្លួនបានយករបស់អ្វីទៅចាក់គេនោះទេ។ រឿងហេតុកើតឡើងដោយសារគប់មាន់។ ខ្លួនសំណូមពរសុំឱ្យតុលាការរក្សាសាលក្រមដើម ទុកនៅដដែល។

-តំណាងអយ្យការសន្និដ្ឋាន បានសន្និដ្ឋានថា ពិតជាមានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ បានប្រព្រឹត្តបទ **ហិង្សាដោយចេតនា** ពិតប្រាកដមែន និងសុំរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរជាមូលដ្ឋាន ។

-តាមសាលក្រមព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់តុលាការខេត្តកណ្តាល បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិក្បាលកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងត្រូវផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ និងផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ដាក់ពន្ធនាគាររយៈពេល ០៣ (បី) ឆ្នាំ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ ត្រូវបាននគរបាលយុត្តិធម៌ធ្វើការចាប់ខ្លួន យកមកអនុវត្តទោសតាមសាលក្រមព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់តុលាការខេត្តកណ្តាល តែជនជាប់ចោទរូបនេះបានប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌ ខាងលើដោយពុំមានភស្តុតាងថ្មីៗ ដាក់ជូនតុលាការដើម្បីពិចារណា ហើយនាពេលសវនាការចំពោះមុខជនជាប់ចោទ ជនជាប់ចោទបានសារភាពនូវអំពើ

របស់ខ្លួនដែលបានប្រព្រឹត្តនៅភូមិក្បាលកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ប្រាកដមែន ដូច្នេះ តុលាការ គប្បីរក្សាតំកល់សេចក្ដីសម្រេចនូវក្នុងខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ ទុកជាបានការទាំងស្រុង ប៉ុន្តែកែប្រែនូវចំណុចផ្ដន្ទាទោសពិរុទ្ធជន មួយចំនួន។

**<u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្ដី</u>**

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការដដែល ប៉ុន្តែកែប្រែនូវចំណុចផ្ដន្ទាទោសលើឈ្មោះ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ មក ០២ (ពីរ) ឆ្នាំ វិញ ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិក្បាលកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខពិរុទ្ធជនឈ្មោះ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ។

ទុកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ ហត្ថលេខា និងត្រា** **ចៅក្រមជំនុំជម្រះ ហត្ថលេខា និងត្រា**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្ដាល.ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រមជំនុំជម្រះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

_សំណុំរឿងព្រហ្មទណ្ឌលេខ:
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨
លេខ:

# គោរពជូន

ឯកឧត្តមប្រធានសាលាឧទ្ធរណ៍ភ្នំពេញ

| ល.រ | ឯកសារភ្ជាប់ | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ១ | សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្ដាល។ | ០១សំណុំរឿង | "ដើម្បីចាត់ការជាសមត្ថកិច្ចតាមនីតិវិធីច្បាប់" |
| ២ | ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ របស់មេធាវី និងមេធាវី ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ ។ | ០១ច្បាប់ | |
| ៣ | សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។ | ០១ច្បាប់ | |
| | សរុប ចំនួន | ០២ច្បាប់ និង ០១សំណុំរឿង | |

ថ្ងៃ...០៦ ៣កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្ដាល, ថ្ងៃទី...០៦.. ខែ វិច្ឆិកា ឆ្នាំ ២០២០

ប្រធានសាលាដំបូង